# សៀវភៅណែនាំអនុវត្តសម្រាប់សង្គមស៊ីវិល
# របៀបតាមដានបន្តលើអនុសាសន៍ស្ដីពីសិទ្ធិមនុស្សរបស់សហប្រជាជាតិ
# ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

*‟នេះជាសំណៅបកប្រែក្រៅផ្លូវការ ពីសំណៅដើមជាភាសាអង់គ្លេស របស់អង្គការសហប្រជាជាតិ។ សំណៅបកប្រែក្រៅផ្លូវការនេះ រៀបចំដោយគម្រោងមួយ របស់គណកម្មាការអ្នកច្បាប់អន្តរជាតិ (ICJ) ក្រោមការជំនួយថវិកាពីការិល័យបរទេស និង រដ្ឋាភិបាលនៃចក្រភពអង់គ្លេស”។*

## មាតិការ


1. របៀបប្រើប្រាស់សៀវភៅណែនាំនេះ....................4
2. តើអ្វីជាការតាមដានបន្ត? ហេតុអ្វីវាមានសារៈសំខាន់?....................5
3. តើត្រូវតាមដានបន្តលើអ្វីខ្លះ?....................6
4. វិធីសាស្ត្រ និងសកម្មភាពតាមដានបន្ត....................8
4.1 ការកំណត់យន្តការចូលរួម....................9
4.2 ការចូលរួមជាមួយយន្តការសិទ្ធិមនុស្សក្នុងរដ្ឋទាំងមូលដើម្បីបង្កើនផលប៉ះពាល់....................10
4.3 ការរៀបចំអនុសាសន៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធផលរកឃើញ....................10
4.4 ការកំណត់អាទិភាព និងការរៀបចំផែនការ....................12
4.5 ការពិនិត្យតាមដានការអនុវត្ត....................17
4.6 ការចាប់យកចំណាប់អារម្មណ៍....................20
4.7 ការបង្កើត និងសហការជាមួយសម្ព័ន្ធនានា....................21
4.8 ភាពជាដៃគូ....................24
4.9 ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង....................27
4.10 ការតស៊ូមតិ....................30
4.11 ការកសាង និងពង្រឹងសមត្ថភាព....................32
4.12 ការបញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងសកម្មភាពតាមដានបន្ត....................34
4.13 ការឆ្លុះបញ្ចាំងលើការរួមបញ្ចូល ភាពចម្រុះ និងភាពអាចទទួលបាន....................35
4.14 ការប្រើប្រាស់អនុសាសន៍ក្នុងសកម្មភាពតុលាការ និងបណ្តឹង....................35
4.15 ការចែករំលែកលទ្ធផលនៃសកម្មភាពតាមដានបន្ត និងការអនុវត្តល្អ....................36
4.16 ការចូលរួមក្នុងនីតិវិធីតាមដានបន្តមានស្រាប់ និងការអនុវត្តយន្តការសិទ្ធិមនុស្ស....................37
5. នីតិវិធីតាមដានបន្ត និងការអនុវត្តយន្តការសិទ្ធិមនុស្ស....................38
5.1 សន្ធិសញ្ញាសិទ្ធិមនុស្ស....................38
5.2 ក្រុមប្រឹក្សាសិទ្ធិមនុស្ស....................43
5.3 នីតិវិធីពិសេស....................45
5.4 ការពិនិត្យឡើងវិញតាមដំណាក់កាលជារួម....................54
5.5 វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ....................57
5.6 ការសងសឹក....................57

6. ការស្វែងយល់បន្ថែម.....60
7. ព័ត៌មានទំនាក់ទំនង.....62

## 1. របៀបប្រើប្រាស់សៀវភៅណែនាំនេះ

សៀវភៅណែនាំនេះ ដែលតាក់តែងឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ផ្តោតលើរបៀបដែលសង្គមស៊ីវិលអាចតាមដានបន្តលើអនុសាសន៍ក្នុងយន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិ និងអាណត្តិ ឬស្ថាប័នពាក់ព័ន្ធ។ អ្នកអានដែលមិនទាន់យល់ច្បាស់ពីលក្ខណៈសំខាន់ៗនៃយន្តការទាំងនេះ គួរអានសៀវភៅណែនាំសម្រាប់សង្គមស៊ីវិលរបស់ OHCHR ៖ ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សរបស់សហប្រជាជាតិ និងសៀវភៅណែនាំអនុវត្តសម្រាប់សង្គមស៊ីវិល[1]។

ផ្នែក 1-3 នៃសៀវភៅណែនាំនេះពន្យល់ពី "ការតាមដានបន្ត" និង "ការអនុវត្ត" ចំណែកផ្នែកទី 4 ពិពណ៌នាពីវិធីសាស្ត្រ និងសកម្មភាពដែលតួអង្គសង្គមស៊ីវិល (CSA) អាចប្រើប្រាស់បាន។ ផ្នែកទី 5 បង្ហាញពីនីតិវិធីតាមដានបន្តមានស្រាប់ និងការអនុវត្តយន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិ និងរបៀបដែលតួអង្គសង្គមស៊ីវិលអាចចូលរួមបាន។

សៀវភៅណែនាំនេះ ក៏នឹងបង្ហាញពីឧបករណ៍សម្រាប់សម្របសម្រួលសកម្មភាពតាមដានបន្តរបស់សង្គមស៊ីវិលផងដែរ ដែលមានរៀបរាប់ក្នុងផ្នែកទី 6។

តាមរយៈការពិនិត្យឡើងវិញលើវិធីសាស្ត្រ និងសកម្មភាពតាមដានបន្តជាច្រើនបូករួមនឹងបទពិសោធន៍ជាក់ស្តែង ដែលផ្តល់ដោយតួអង្គសង្គមស៊ីវិល[2] និងការងារតាមមូលដ្ឋានរបស់ OHCHR សៀវភៅណែនាំនេះនឹងផ្តល់ជម្រើសជាច្រើនដែលតួអង្គសង្គមស៊ីវិល អាចជ្រើសរើសមកអនុវត្តទៅតាមអាទិភាព និងសមត្ថភាពរបស់ខ្លួន។

សៀវភៅណែនាំនេះផ្តោតសំខាន់លើតួអង្គសង្គមស៊ីវិលដែលបំពេញការងារនៅថ្នាក់ជាតិ។ សៀវភៅណែនាំនេះមានជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ។

---

[1] មានក្នុង ៖ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

[2] ការរួមបញ្ចូលករណីសិក្សាមិនបង្ហាញពីមតិឯកភាពរបស់ OHCHR ឡើយ។

2. តើអ្វីជាការតាមដានបន្ត? ហេតុអ្វីវាមានសារៈសំខាន់?

សកម្មភាពតាមដានបន្តផ្តោតលើការធានាថា អនុសាសន៍ និងសេចក្តីសម្រេចចិត្តរបស់យន្តការ និងស្ថាប័នសិទ្ធិមនុស្សត្រូវបានអនុវត្តដើម្បីលើកកម្ពស់ការគោរព ការការពារ និងការបំពេញសិទ្ធិមនុស្សជារួម។

យន្តការ និងស្ថាប័នសិទ្ធិមនុស្សរបស់សហប្រជាជាតិសំដៅបង្កើនការសម្រេចបានសិទ្ធិមនុស្សក្នុងប្រទេសទាំងអស់នៅជុំវិញពិភពលោក។ សេចក្តីសម្រេចដែលអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស លទ្ធផលរកឃើញរបស់គណៈកម្មការស៊ើបអង្កេត អនុសាសន៍របស់សន្ធិសញ្ញា នីតិវិធីពិសេស និងការពិនិត្យឡើងវិញតាមដំណាក់កាលជារួម និងសេចក្តីសម្រេចរបស់សន្ធិសញ្ញាពាក់ព័ន្ធនឹងករណីនីមួយៗ សុទ្ធតែសំដៅលុបបំបាត់ចំណុចខ្វះខាតក្នុងការការពារ និងបង្ហាញផ្លូវសម្រាប់ឲ្យបណ្តារដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតពន្លឿនការសម្រេចបានសិទ្ធិមនុស្សពេញលេញ។ លទ្ធផលរកឃើញ អនុសាសន៍ និងសេចក្តីសម្រេចទាំងអស់នេះ សំដៅបង្កើតឲ្យមានការផ្លាស់ប្តូរជីវិតល្អប្រសើររបស់អ្នកមានសិទ្ធិ។ កាតព្វកិច្ចចម្បងក្នុងការសម្រេចបានការផ្លាស់ប្តូរនេះផ្អែកលើបណ្តារដ្ឋ ដែលមានកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិមនុស្ស។ យ៉ាងនេះក្តី សង្គមគ្រប់ផ្នែក ចាប់ពីបុគ្គលរហូតដល់វិស័យឯកជន សហគមន៍អន្តរជាតិ និងតួអង្គសង្គមស៊ីវិល សុទ្ធតែមានតួនាទីសម្រេចបានសិទ្ធិមនុស្ស។ សំខាន់បំផុត សង្គមស៊ីវិលអាចដើរតួនាទីជាក់ស្តែងក្នុងការតាមដានបន្តលើអនុសាសន៍ស្តីពីសិទ្ធិមនុស្ស។

ដំណាក់កាលសង្ខេបនៃការតាមដានបន្ត




## 3. តើត្រូវតាមដានបន្តលើអ្វីខ្លះ?

លទ្ធផលរកឃើញ និងអនុសាសន៍របស់យន្តការ និងស្ថាប័នសិទ្ធិមនុស្សរបស់សហប្រជាជាតិមានច្រើនអនេក។ សង្គមស៊ីវិលតាមដានបន្តលើលទ្ធផលរកឃើញ និងអនុសាសន៍ដែលពាក់ព័ន្ធនឹងគោលបំណង និងវិសាលភាពសកម្មភាពរបស់ខ្លួន ដូចខាងក្រោម ៖

- អនុសាសន៍ដែលអនុម័តដោយសន្និសញ្ញាក្នុងការសង្កេតរួម ក្រោយការពិនិត្យលើការអនុវត្តសន្និសញ្ញាសិទ្ធិមនុស្សដោយរដ្ឋភាគីមួយ
- អនុសាសន៍ដែលផ្តល់ដោយនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលមានក្នុងរបាយការណ៍ស្តីពីការចុះពិនិត្យតាមប្រទេស របាយការណ៍តាមផ្នែក និងទំនាក់ទំនងទៅតាមករណីនីមួយៗ

- អនុសាសន៍ដែលទទួលបានពីការពិនិត្យឡើងវិញតាមដំណាក់កាលជារួម (UPR) របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងមហាសន្និបាត
- កិច្ចការរបស់ស្ថាប័នផ្សេងៗក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស ដូចជា គណៈកម្មាធិការប្រឹក្សានីតិវិធីបណ្តឹង យន្តការជំនាញស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច វេទិកាស្តីពីបញ្ហារបស់ជនជាតិភាគតិច វេទិកាសង្គម និងវេទិកាស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស
- អនុសាសន៍របស់គណៈកម្មការស៊ើបអង្កេត បេសកកម្មស្វែងរកការពិត និងយន្តការស៊ើបអង្កេតសិទ្ធិមនុស្សបណ្តោះអាសន្នផ្សេងទៀត ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ឬអគ្គលេខាធិការសហប្រជាជាតិ
- អនុសាសន៍ក្នុងរបាយការណ៍ និងការសិក្សារបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ឧ. របាយការណ៍សកម្មភាពតាមមូលដ្ឋាន របាយការណ៍ និងការសិក្សាតាមប្រទេស និងស្ថានភាពតាមផ្នែកដែលកំណត់អាណត្តិដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស)
- ការអំពាវនាវទៅរដ្ឋភាគី ឬសហគមន៍អន្តរជាតិដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ឬអ្នកជំនាញសិទ្ធិមនុស្សឯករាជ្យក្នុងសេចក្តីថ្លែងការណ៍សាធារណៈ។

នេះជាបញ្ជីមិនលម្អិតស្តីពីអនុសាសន៍សម្រាប់ការតាមដានបន្តរបស់រដ្ឋ និងសង្គមស៊ីវិល។ ក្រៅពីយន្តការរបស់សហប្រជាជាតិ យន្តការសិទ្ធិមនុស្សថ្នាក់តំបន់ និងថ្នាក់ជាតិ ក៏បានចេញរបាយការណ៍ និងអនុសាសន៍សំដៅបង្កើនការសម្រេចបានសិទ្ធិមនុស្សផងដែរ។

ក្នុងការសម្រេចចិត្តលើចំណុចផ្តោត ត្រូវបញ្ចៀសការតាមដានបន្តក្នុងលក្ខណៈមិនជាប់លាប់។ ខណៈដែលយន្តការសិទ្ធិមនុស្សផ្សេងៗសុទ្ធតែមាននីតិវិធីតាមដានបន្តផ្ទាល់ខ្លួន និងការអនុវត្តដែលមានរៀបរាប់ក្នុងផ្នែកទី 5 នៃសៀវភៅណែនាំនេះ តម្លៃបន្ថែមមួយដែលសង្គមស៊ីវិលអាចយកទៅអនុវត្តបានគឺការតាមដានបន្តដោយប្រើប្រាស់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ។

វិធីសាស្ត្រគ្រប់ជ្រុងជ្រោយប្រើប្រាស់យន្តការសិទ្ធិមនុស្សចម្រុះ ជាជាងផ្តោតលើអនុសាសន៍តែមួយ។ វិធីសាស្ត្រនេះផ្តោតលើការពាក់ព័ន្ធនឹងយន្តការសិទ្ធិមនុស្សក្នុងគ្រប់ដំណាក់កាលទាំងអស់នៃ

ការងារ។ យន្តការសិទ្ធិមនុស្សធ្វើការក្នុងលក្ខណៈជាវដ្តដែលអាចធ្វើឲ្យមានលក្ខណៈសាមញ្ញក្នុងដំណាក់កាលនៃការប្រមូលព័ត៌មាន រាយការណ៍ កិច្ចសន្ទនាជាមួយរដ្ឋពាក់ព័ន្ធ អនុសាសន៍ និងការតាមដានបន្ត។

ដូច្នេះ ការតាមដានបន្តរបស់សង្គមស៊ីវិលកាន់តែមានប្រសិទ្ធភាពនៅពេលសកម្មភាពនេះពាក់ព័ន្ធនឹងដំណើរទាំងមូល។ ខណៈដែលការរក្សាទំនាក់ទំនងក្នុងដំណាក់កាលទាំងអស់នៃវដ្តសកម្មភាពរបស់យន្តការសិទ្ធិមនុស្សនឹងផ្តល់លទ្ធផលកាន់តែច្រើន តួអង្គសង្គមស៊ីវិលអាចទទួលបានប្រយោជន៍ពីលទ្ធផលសម្រេច និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស ទោះបីជាមិនធ្លាប់ចូលរួមពីមុនក៏ដោយ។

**វដ្តនៃយន្តការសិទ្ធិមនុស្ស**




## 4. វិធីសាស្ត្រ និងសកម្មភាពតាមដានបន្ត

ផ្នែកនេះបង្ហាញពីវិធីសាស្ត្រ និងសកម្មភាពមួយចំនួនសម្រាប់ការតាមដានបន្តរបស់សង្គមស៊ីវិលបូករួមនឹងឧទាហរណ៍មួយចំនួនស្តីពីការអនុវត្តកន្លងមក។

### 4.1 ការកំណត់យន្តការចូលរួម

ការសម្រេចបានសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប គឺជាគោលដៅរួមសម្រាប់ស្ថាប័នសិទ្ធិមនុស្សសហប្រជាជាតិទាំងអស់។ ក្នុងប្រទេសភាគច្រើន វឌ្ឍនភាពកើតចេញកត្តាជាច្រើន ចាប់ពីឆន្ទៈនយោបាយរបស់អ្នកមានកាតព្វកិច្ចរហូតដល់ការប្រព្រឹត្តរបស់ភ្នាក់ងារអនុវត្តច្បាប់ សកម្មភាពរបស់សង្គមស៊ីវិល សេចក្តីសម្រេចចិត្ត និងកម្រិតឯករាជ្យភាពរបស់តុលាការ ឥទ្ធិពលរបស់អង្គការថ្នាក់តំបន់ ការផ្លាស់ប្តូរក្នុងរដ្ឋាភិបាល។ល។ OHCHR និងយន្តការសិទ្ធិមនុស្សសហប្រជាជាតិអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួសត្រាយផ្លូវឆ្ពោះទៅរកការអនុវត្ត។




តើយន្តការមួយណាដែលមានផលប៉ះពាល់ខ្លាំងបំផុត? ការចុះពិនិត្យតាមប្រទេសដោយអ្នកមានអាណត្តិលើនីតិវិធីពិសេស? អនុសាសន៍លើកឡើងដោយបណ្តារដ្ឋក្នុងការពិនិត្យឡើងវិញតាមដំណាក់កាលជារួម (UPR) និងដំណើរការនយោបាយពាក់ព័ន្ធ? ឬតើវាជាសេចក្តីសម្រេចលើបណ្តឹងនីមួយៗដោយសន្ធិសញ្ញាមួយ? ប្រហែលជា ចំណុចទាំងអស់នេះ និងចំណុចផ្សេងទៀត? តើយន្តការសិទ្ធិមនុស្សអាចផ្តល់តម្លៃបន្ថែមអ្វីដល់ការងាររបស់សង្គមស៊ីវិល ដែលពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្សតាមផ្នែក និង/ឬ ក្នុងប្រទេស តំបន់ ឬដែនដីមួយ? តើការចូលរួមជាមួយយន្តការសិទ្ធិមនុស្សស៊ីសង្វាក់គ្នានឹងអាទិភាព ផែនការ និងសមត្ថភាពរបស់តួអង្គសង្គមស៊ីវិល ឬទេ?

ការវិភាគលើអ្វីដែលយន្តការមួយអាចផ្តល់ឲ្យ និងការយល់ពីលទ្ធផលរកឃើញ និងអនុសាសន៍ គឺជាជំហានសំខាន់ៗក្នុងការ ៖ 1) ធ្វើសេចក្តីសម្រេចលើការចូលរួមរបស់សង្គមស៊ីវិលជាមួយយន្តការនោះ 2) ជះឥទ្ធិពលលើការចូលរួមនោះ និង 3) បញ្ចូលការចូលរួមនោះទៅក្នុងយុទ្ធសាស្ត្រ និងផែនការការងាររបស់តួអង្គសង្គមស៊ីវិល។

**4.2 ការចូលរួមជាមួយយន្តការសិទ្ធិមនុស្សក្នុងវដ្តទាំងមូលដើម្បីបង្កើនផលប៉ះពាល់**

បទពិសោធន៍នានាបង្ហាញថា ទំនាក់ទំនងរបស់សង្គមស៊ីវិលជាមួយយន្តការសិទ្ធិមនុស្សផ្តល់លទ្ធផលច្រើននៅពេលពាក់ព័ន្ធនឹងដំណាក់កាលទាំងអស់នៃវដ្តការងាររបស់យន្តការសិទ្ធិមនុស្ស។ ឧ. នៅពេលដាក់ព័ត៌មានសម្រាប់ UPR លើរដ្ឋដែលត្រូវពិនិត្យឡើងវិញ សង្គមស៊ីវិលអាចផ្តោតលើបញ្ហាដែលបង្កជាកង្វល់បំផុត ដូចជា ទណ្ឌកម្មលើរាងកាយកុមារ ឬការរើសអើងជនជាតិភាគតិច។ ដំបូងពួកគេអាចបង្កើតជាកិច្ចសន្ទនាជាមួយរដ្ឋាភិបាលសាមី រួចទើបរៀបចំកិច្ចសន្ទនាជាមួយគណៈប្រតិភូនៃរដ្ឋសមាជិកដែលនឹងចូលរួមក្នុងកិច្ចសន្ទនាអន្តរសកម្មរបស់ UPR និងជំរុញឲ្យពួកគេលើកឡើងជាអនុសាសន៍ស្តីពីបញ្ហាទាំងនេះ។ ឯកសារលទ្ធផលសម្រេចរបស់ UPR នឹងឆ្លុះបញ្ចាំងពីអនុសាសន៍ទាំងនេះ និងអាចត្រូវបានប្រើប្រាស់នៅថ្នាក់ជាតិដើម្បីពង្រឹងការតស៊ូមតិ ឬសកម្មភាពផ្សេងទៀតរបស់សង្គមស៊ីវិល។

ដំណើរការស្រដៀងគ្នាធ្វើឡើងជាមួយយន្តការផ្សេងទៀត ដូចជា ការចែកចាយព័ត៌មានចងក្រងពេញលេញ និងអាចទុកចិត្តបានស្តីពីបញ្ហាកង្វល់ដែលសង្គមស៊ីវិលបង្កើនលទ្ធភាពទទួលបានលទ្ធផលរកឃើញ និងអនុសាសន៍ដែលពាក់ព័ន្ធ និងជាចំណុចផ្តោត។ អនុសាសន៍ដែលពេញលេញអាចអនុវត្តបាន ឆ្លើយតបនឹងចំណុចខ្វះខាតក្នុងការការពារសិទ្ធិមនុស្ស ដែលផ្តល់ដោយស្ថាប័នសិទ្ធិមនុស្សសហប្រជាជាតិគឺជាកត្តាសំខាន់ក្នុងការគាំទ្រការតស៊ូមតិរបស់សង្គមស៊ីវិលនៅថ្នាក់ជាតិ។

**4.3 ការរៀបចំអនុសាសន៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធផលរកឃើញ**

អនុសាសន៍ និងលទ្ធផលរកឃើញរបស់យន្តការសិទ្ធិមនុស្ស ទាំងផ្អែកតាមប្រទេស និងតាមផ្នែកមានច្រើនអនេក។ ការចងក្រ និងប្រមូលផ្តុំអនុសាសន៍ និងលទ្ធផលរកឃើញទាំងនេះទៅតាមផ្នែក ឬភូមិសាស្ត្រ អាចជាការរៀបចំដ៏មានប្រយោជន៍សម្រាប់វិធីសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការតាមដានបន្ត។ ការរៀបចំអនុសាសន៍ និងលទ្ធផលរកឃើញ អាច ៖

- សម្របសម្រួលលទ្ធភាពទទួលបានអនុសាសន៍

- ជួយបង្កើនការយល់ដឹង និងផ្សព្វផ្សាយអនុសាសន៍
- ជួយបង្កើតខ្លឹមសាររួមទូលំទូលាយនៃអនុសាសន៍មានស្រាប់ និងផ្ដល់មូលដ្ឋានសម្រាប់យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនៃការតាមដានបន្ត
- សម្របសម្រួលការកំណត់អាទិភាពក្នុងការអនុវត្ត និងតាមដានបន្ត
- ជាមូលដ្ឋាននៃការបង្កើតផែនការពិនិត្យតាមដាន។

ឧបករណ៍ខាងក្រោមអាចជួយដល់ដំណើរការនេះ ៖

**សន្ទស្សន៍សិទ្ធិមនុស្សជាសកល**

**សន្ទស្សន៍សិទ្ធិមនុស្សជាសកល**[3] គឺជាមូលដ្ឋានទិន្នន័យតាមអ៊ីនធើរណែតដែលចងក្រងអនុសាសន៍ពីសន្ធិសញ្ញា នីតិវិធីពិសេស និង UPR។ សន្ទស្សន៍នេះអាចឲ្យអ្នកប្រើប្រាស់ពិនិត្យ និងស្រាវជ្រាវសន្ធិសញ្ញា នីតិវិធីពិសេស និងអនុសាសន៍ UPR ទៅតាមប្រភេទជាច្រើន ៖ រដ្ឋ សិទ្ធិ ស្ថាប័ន អ្នករងផលប៉ះពាល់ ពេលវេលាកំណត់ និងសម្រាប់ UPR រដ្ឋដែលផ្ដល់អនុសាសន៍ គោលជំហររបស់រដ្ឋដែលត្រូវពិនិត្យឡើងវិញ និងកិច្ចប្រជុំ។ ដោយគ្រាន់តែចុចគ្លីកប៊ូតុងប៉ុណ្ណោះ អ្នកប្រើប្រាស់អាចបើកមើលការវាយតម្លៃដោយស្ថាប័ន និងយន្តការរបស់សហប្រជាជាតិស្ដីពីស្ថានភាពនៃការអនុវត្តសិទ្ធិមនុស្សក្នុងស្ថានភាពណាមួយ។ ការណ៍នេះនឹងផ្ដល់ព័ត៌មានមានស្រាប់ជាច្រើនរបស់សហប្រជាជាតិស្ដីពីសិទ្ធិមនុស្សដែលកាន់តែមានតម្លាភាព និងអាចទទួលបាន។

**កម្រងអនុសាសន៍ក្នុងអាស៊ីកណ្ដាល**

ក្នុងប្រទេស Krygyzstan ការិយាល័យថ្នាក់តំបន់ប្រចាំអាស៊ីកណ្ដាលរបស់ OHCHR បានគាំទ្រស្ថាប័នស្រាវជ្រាវមួយ ក្នុងការបង្កើតកម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិទៅតាមសិទ្ធិ ដូចជា អនុសាសន៍ដែលទទួលបានពីសន្ធិសញ្ញា នីតិវិធីពិសេស និង UPR។ វាក្លាយជាមូលដ្ឋានក្នុងការរៀបចំផែនការការងារស្ដីពីការអនុវត្តអនុសាសន៍[4]។

---

[3] http://uhri.ohchr.org/

[4] ការចងក្រងនេះមានក្នុងគេហទំព័រ ៖ www.auca.kg

### 4.4 ការកំណត់អាទិភាព និងការរៀបចំផែនការ

តួអង្គសង្គមស៊ីវិលអាចរកឃើញថា អនុសាសន៍មួយចំនួនមានភាពពាក់ព័ន្ធជាងអនុសាសន៍ផ្សេងទៀត។ អនុសាសន៍ខ្លះអាចផ្តោតលើអាទិភាពតាមផ្នែក ឬភូមិសាស្ត្ររបស់តួអង្គសង្គមស៊ីវិល។ ទន្ទឹមនឹងនេះ អនុសាសន៍ខ្លះអាចនឹងងាយពិនិត្យតាមដានបន្ត ចំណែកអនុសាសន៍ផ្សេងទៀតត្រូវការធនធានដែលមិនទាន់មាន។ អនុសាសន៍ខ្លះអាចជាលទ្ធផលនៃការងាររៀបចំរបស់សង្គមស៊ីវិលជាមួយយន្តការសិទ្ធិមនុស្សមួយ។ ការតាមដានបន្តលើអនុសាសន៍ទាំងនេះងាយនឹងត្រូវបានកំណត់អាទិភាព និងបញ្ចូលទៅក្នុងយុទ្ធសាស្ត្រ និងផែនការការងាររបស់តួអង្គសង្គមស៊ីវិល។

**ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយតួអង្គឯកជនក្នុងប្រទេសកាណាដា**

នៅឆ្នាំ 2011 ក្លឹបចំនួន 110 របស់ Canadian Federation of University of Women (CFUW) បានជំរុញឲ្យរដ្ឋាភិបាលកាណាដាដាក់ទោសឧក្រិដ្ឋលើទារុណកម្ម ដែលបង្កឡើងដោយតួអង្គឯកជន។

ក្រមព្រហ្មទណ្ឌកាណាដាកំណត់ឲ្យតួអង្គរដ្ឋដាក់ទារុណកម្មលើជនបង្ក។ នៅពេលបុគ្គលប្រឈមនឹងទារុណកម្មដូចគ្នាដែលបង្កឡើងដោយបុគ្គលឯកជន ដូចជា ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ បុគ្គលទាំងនេះត្រូវទទួលខុសត្រូវពីបទឧក្រិដ្ឋទារុណកម្ម។

នៅខែមេសា ឆ្នាំ 2012 CFUW បានដាក់របាយការណ៍អមមួយ (shadow report) ទៅគណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម (CAT)។ សមាជិករបស់ CFUW បានចូលរួមក្នុងកិច្ចប្រជុំកាលពីខែ ឧសភា របស់គណៈកម្មាធិការនេះនៅទីក្រុងហ្សឺណែវ។ សមាជិក CFUW ពីររូបបាននិយាយថា "យើងបានលឺថា គណៈកម្មាធិការបញ្ជាក់ចំពោះគណៈប្រតិភូរដ្ឋាភិបាលកាណាដាថា ទម្រង់មួយចំនួននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រគឺជាសញ្ញាណនៃទារុណកម្ម នៅពេលបង្កឡើងដោយតួអង្គមិនមែនរដ្ឋ ហើយអំពើទាំងនេះស្ថិតក្នុងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងអំពើព្រៃផ្សៃផ្សេងទៀត អំពើអមនុស្សធម៌ ឬការប្រមាថមើលងាយ ឬទណ្ឌកម្ម។ វាគឺជាចំណុចវិជ្ជមានថ្មីមួយសម្រាប់សមភាពយេនឌ័រ ហើយសិទ្ធិមនុស្សដែលមិនអាចតវ៉ាបានរបស់ស្ត្រី និងក្មេងស្រី មិនត្រូវប្រឈមនឹងទារុណកម្មដែលបង្កឡើងដោយតួអង្គមិនមែនរដ្ឋឡើយ។ ការសង្កេតរួមរបស់ CAT គឺជាចំណុចរបត់ថ្មីមួយសម្រាប់ពួកយើង ហើយយើងអាចប្រើប្រាស់វាក្នុងការងាររបស់យើង"។ នៅពេលតាមដានបន្តលើការសង្កេតរួមរបស់គណៈកម្មាធិការនេះ CFUW បានដាក់សេចក្តីថ្លែងការណ៍ជា

លាយលក្ខណ៍អក្សរទៅគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី និងគាំទ្រឲ្យមានការដាក់ UPR របស់កាណាដាដោយផ្អែកលើការសង្កេតរួមរបស់ CAT ស្តីពីទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដែលបង្កឡើងដោយតួអង្គឯកជន។

នៅពេលមាន ឬគ្មានការចូលរួមក្នុងដំណាក់កាលមុននៃវដ្តការងាររបស់យន្តការសិទ្ធិមនុស្ស តួអង្គសង្គមស៊ីវិលរកឃើញថា ការកំណត់អាទិភាពអនុសាសន៍ និងលទ្ធផលរកឃើញមានស្រាប់ដោយកំណត់រកអនុសាសន៍ ឬលទ្ធផលរកឃើញដែលពាក់ព័ន្ធនឹងគោលដៅសិទ្ធិមនុស្សរបស់ពួកគេ គឺជាជំហានដ៏សំខាន់ក្នុងការបង្កើតផែនការតាមដានបន្តជាក់ស្តែង។ តួអង្គសង្គមស៊ីវិលអាចប្រើប្រាស់កម្រងលក្ខណវិនិច្ឆ័យផ្សេងៗដើម្បីកំណត់អាទិភាពអនុសាសន៍ដូចខាងក្រោម ៖

- អនុសាសន៍របស់យន្តការសិទ្ធិមនុស្ស ឬស្ថាប័នដែលពង្រឹងការអនុវត្តអនុសាសន៍របស់តួអង្គសង្គមស៊ីវិល
- អនុសាសន៍ដែលស្របនឹងគោលបំណង និងសកម្មភាពរបស់តួអង្គសង្គមស៊ីវិលដែលអាចរួមបញ្ចូលការតាមដានបន្តរបស់ខ្លួនទៅក្នុងផែនការការងារ
- អនុសាសន៍ និងលទ្ធផលរកឃើញដែលកំណត់នូវភាពជឿនលឿនថ្មីក្នុងការបកស្រាយ និងអនុវត្តច្បាប់ស្តីពីសិទ្ធិមនុស្ស
- អនុសាសន៍ដែលការអនុវត្តអាចធ្វើទៅបានដោយសារកត្តាជាច្រើន (ឧ. កំណត់អាទិភាពដោយរដ្ឋសម្រាប់ការអនុវត្ត សម្ពាធ និង/ឬជំនួយរបស់សហគមន៍អន្តរជាតិ ការមានធនធាន)
- អនុសាសន៍ដែលសង្គមស៊ីវិលអាចតាមដានបន្តដោយសហការជាមួយសម្ព័ន្ធផ្សេងទៀត
- អនុសាសន៍ដែលការអនុវត្តអាចវាស់វែងបានដោយតួអង្គសង្គមស៊ីវិល
- អនុសាសន៍ដែលត្រូវបានផាត់ចោលដោយគ្មានសកម្មភាពរបស់តួអង្គសង្គមស៊ីវិល និង
- អនុសាសន៍ដែលលើកឡើងចំពោះសង្គមស៊ីវិល (ឧ. អនុសាសន៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ដែលលើកឡើងចំពោះសហគមន៍របស់អ្នកការពារ”។

**ការកំណត់អាទិភាពអនុសាសន៍ UPR ពាក់ព័ន្ធនឹងការមិនរើសអើងដោយផ្អែកលើយេនឌ័រ និងអត្តសញ្ញាណយេនឌ័រ**

លំហាត់ស្តីពីការកំណត់អាទិភាពអនុសាសន៍ UPR និងការបង្កើតផែនការការងារបឋមអាចមានខ្លឹមសារសង្ខេបដូចខាងក្រោម ៖

| អនុសាសន៍ UPR | ត្រូវបានកំណត់អាទិភាព? | ប្រភេទការតាមដានបន្ត និងសកម្មភាពសំខាន់ៗ | អង្គការទទួលខុសត្រូវ និងធនធាន | រយៈពេលកំណត់ | សូចនាករ |
|---|---|---|---|---|---|
| ពង្រឹងការការពារផ្លូវច្បាប់ប្រឆាំងនឹងការរើសអើងដើម្បីរួមបញ្ចូលនិន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រជាមូលដ្ឋានហាមឃាត់ការរើសអើង | មែនៗ ការចំណុចខ្វះខាតសំខាន់ដែលរដ្ឋាភិបាលអាចមើលរំលងប្រសិនបើមិនជំរុញដោយតួអង្គសង្គមស៊ីវិល និងសហគមន៍អន្តរជាតិ | ការតស៊ូមតិ ការបញ្ចុះបញ្ចូលសមាជិកសភាចូលរួមក្នុងការព្រាងច្បាប់យុទ្ធនាការ | LGBT អង្គការដែលសហការជាមួយតួអង្គសង្គមស៊ីវិលផ្សេងទៀតៗ ផ្អែកនៃសកម្មភាពបន្តបន្ទាប់ៗ | រយៈពេល 4 ឆ្នាំបន្ទាប់ | និន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រត្រូវបានរួមបញ្ចូលជាមូលដ្ឋានហាមឃាត់ការរើសអើងក្នុងច្បាប់ប្រឆាំងការរើសអើងៗ |
| ផ្តួចផ្តើម ឬចូលរួមក្នុងយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈដើម្បីជំរុញឲ្យមានការអត់អោនចំពោះមនុស្សស្រឡាញ់ភេទដូចគ្នា មនុស្ស | មែនៗ សូមមើលផ្នែកខាងលើ | ចូលរួមក្នុងយុទ្ធនាការៗ ស្នើដល់យុវជនគោលដៅសាធារណជន និងភ្នាក់ងារអនុវត្តច្បាប់ៗ បរិយាកាស | LGBT អង្គការដែលសហការជាមួយតួអង្គសង្គមស៊ីវិលផ្សេងទៀតៗ ធនធានចាំបាច់បន្ថែមទៀត | 4 ឆ្នាំបន្ទាប់ | យុទ្ធនាការត្រូវបានអនុវត្តប្រភេទក្រុមគោលដៅដែលបានចុះដល់ៗ |

| | | | | | |
|---|---|---|---|---|---|
| ស្រឡាញ់ទាំងពីរភេទ និងមនុស្សខ្ទើយ។ | | ដែលត្រូវផ្តោតសំខាន់ ៖ សាលាមធ្យមសិក្សា សាកលវិទ្យាល័យ ក្លឹបកីឡា មជ្ឈមណ្ឌលបណ្តុះបណ្តាលនគរបាល។ | | | |
| បន្តដោះស្រាយវិសមភាពយេនឌ័រ | ទេ។ ត្រូវបានបង្កើតឡើងដោយមិនច្បាស់លាស់ទាល់តែសោះ។ | | | | |
| បន្តពង្រឹងស្ថាប័ន និងគោលនយោបាយទប់ស្កាត់ដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងការរើសអើងស្ត្រី។ | មែន។ រដ្ឋាភិបាលគួរត្រូវបានជំរុញឲ្យពង្រឹងស្ថាប័នសមភាពដោយផ្តល់ធនធានបន្ថែម។ | ការពិនិត្យតាមដាន និងតស៊ូមតិ។ ពិនិត្យតាមដានធនធានថវិកាបែងចែកទៅក្រសួងសម្រាប់ការផ្តល់ឱកាសស្មើភាព។ ពិនិត្យតាមដានគំនិតផ្តួចផ្តើមស្នើឡើងដោយក្រសួងដែលត្រូវ | អង្គការស្ត្រីដែលសហការជាមួយតួអង្គសង្គមស៊ីវិលផ្សេងទៀត។ ផ្នែកនៃសកម្មភាពជាបន្តបន្ទាប់។ ជំនាញបន្ថែមលើការពិនិត្យតាមដានថវិកាចាំបាច់។ | 4 ឆ្នាំបន្ទាប់ | ធនធានដែលត្រូវបានបែងចែកដល់ក្រសួងសម្រាប់ការផ្តល់ឱកាសស្មើភាព។ សំណើគោលនយោបាយដោយក្រសួងដែលអនុម័ត និងអនុវត្តដោយរដ្ឋាភិបាល។ |

| | | | | | |
|---|---|---|---|---|---|
| | | បានយកទៅពិចារណា និងអនុវត្តដោយរដ្ឋាភិបាល។ | | | |
| កំណត់អាទិភាពការអនុវត្តកំណែទម្រង់ច្បាប់ថ្មីៗដើម្បីលុបបំបាត់បទប្បញ្ញត្តិដែលរើសអើងស្ត្រីដោយអនុលោមតាមអនុសញ្ញា CEDAW។ | មែន។ នេះជាពេលដែលត្រូវមានក្របខ័ណ្ឌគតិយុត្តិដែលគ្មានការរើសអើង! | ការពិនិត្យតាមដានច្បាប់។ ផ្នែកនៃសកម្មភាពតាមដានបន្តលើការសង្កេតរួមរបស់អនុសញ្ញា CEDAW។ | អង្គការស្ត្រីដែលសហការជាមួយតួអង្គសង្គមស៊ីវិលផ្សេងទៀត។ ផ្នែកនៃសកម្មភាពបន្តបន្ទាប់។ | របាយការណ៍បន្ទាប់ក្រោមអនុសញ្ញា CEDAW។ | បទប្បញ្ញត្តិមានលក្ខណៈរើសអើងដែលកំណត់ដោយអនុសញ្ញា CEDAW ត្រូវបានទុកជានិរាករណ៍។ |
| ចាត់វិធានការផ្តោតដើម្បីលុបបំបាត់គម្លាតប្រាក់ឈ្នួលរវាងស្ត្រី និងបុរស។ | ទេ ប៉ុន្តែគាំទ្រដោយតួអង្គសង្គមស៊ីវិល។ លើសពីសមត្ថភាពតាមដានបន្តរបស់តួអង្គសង្គមស៊ីវិល។ | | | | |
| បង្កើតយុទ្ធសាស្ត្រលម្អិតដោយសហការជាមួយសង្គមស៊ីវិលដើម្បីលុបបំបាត់ការអនុវត្តផ្នែកវប្បធម៌ដែលបង្កគ្រោះថ្នាក់ និងផ្តត់គំនិតរើសអើងស្ត្រី។ | មែន។ ចំណុចនេះត្រូវបានកំណត់អាទិភាពដោយសម្ព័ន្ធ ហើយអនុសាសន៍បានកំណត់តួនាទីជាក់លាក់ | ចូលរួមក្នុងការបង្កើតយុទ្ធសាស្ត្រ។ | អង្គការស្ត្រីដែលសហការជាមួយអង្គការ UN Women។ | 1 ឆ្នាំ | យុទ្ធសាស្ត្រត្រូវបានអនុម័ត។ |

| | | | | | |
|---|---|---|---|---|---|
| | សម្រាប់សង្គមស៊ីវិល។ | | | | |
| ពង្រឹងកិច្ចខិតខំប្រឹងប្រែងលុបបំបាត់ពលកម្មកុមារ ដោយបង្កើនការសម្របសម្រួលក្នុងចំណោមស្ថាប័នជាតិជាច្រើនដែលដោះស្រាយបញ្ហាសិទ្ធិកុមារ។ | ទេ។ ស្ថិតនៅក្រៅវិសាលភាពសកម្មភាពរបស់តួអង្គសង្គមស៊ីវិលពាក់ព័ន្ធ។ | | | | |

### 4.5 ការពិនិត្យតាមដានការអនុវត្ត

ការពិនិត្យតាមដានការអនុវត្តអនុសាសន៍ដោយរដ្ឋ គឺជាសកម្មភាពដ៏សំខាន់សម្រាប់សង្គមស៊ីវិលក្នុងការធានាគណនេយ្យភាពរបស់រដ្ឋាភិបាល។ វាអាចមានតួអង្គសង្គមស៊ីវិលដែលរក្សាព័ត៌មានបច្ចុប្បន្នភាពអំពីថាតើរដ្ឋបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សជាក់លាក់ បានទទួលយកការស្នើឲ្យមាននីតិវិធីពិសេសដើម្បីចុះពិនិត្យតាមប្រទេស បានអនុម័តច្បាប់ប្រឆាំងការរើសអើង ឬការរៀបចំដំណើរការពិនិត្យតាមដានស្មុគស្មាញពាក់ព័ន្ធនឹងការប្រមូល និងការផ្ទៀងផ្ទាត់ទិន្នន័យជាច្រើនពីប្រភពផ្សេងៗ និងក្នុងទីតាំងចម្រុះ ឬការវិភាគព័ត៌មានពាក់ព័ន្ធនឹងសូចនាករ និងចំណុចដៅក្នុងអំឡុងពេលកំណត់មួយ។ ដោយមិនគិតពីប្រភេទនៃការពិនិត្យតាមដាន (ស្មុគស្មាញ ឬសាមញ្ញ) **លទ្ធផលរកឃើញត្រូវតែត្រឹមត្រូវ និងអាចទុកចិត្តបាន។** លទ្ធផលរកឃើញអាចជាមូលដ្ឋានសម្រាប់ការតស៊ូមតិជាមួយរដ្ឋាភិបាលជាតិ និងអាចបង្កើតឡើងជាសំណើចំពោះយន្តការសិទ្ធិមនុស្ស ដូចជា ក្នុងវដ្តទីពីរ ឬទីបីនៃ UPR សម្រាប់ការពិនិត្យឡើងវិញជាបន្តបន្ទាប់ដោយសន្ធិសញ្ញាដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្ស។ សៀវភៅណែនាំរបស់ OHCHR ស្តីពីការពិនិត្យតាមដានសិទ្ធិមនុស្ស[5] ផ្តល់ការណែនាំលម្អិតស្តីពីវិធីសាស្ត្រពិនិត្យតាមដាន ដូចជា ការប្រមូល ការផ្ទៀងផ្ទាត់ ការវិភាគ និងការប្រើប្រាស់ព័ត៌មានយ៉ាងសកម្មដើម្បីវាយតម្លៃ និងដោះស្រាយបញ្ហាសិទ្ធិ

[5]សៀវភៅណែនាំស្តីពីការពិនិត្យតាមដានសិទ្ធិមនុស្ស (ការបោះពុម្ពផ្សាយរបស់សហប្រជាជាតិ HR/P/PT/7/Rev. 1)។

មនុស្ស។ យោងតាមកំណត់នេះ ការពិនិត្យតាមដានធ្វើឡើងក្នុងអំឡុងពេលអូសបន្លាយ។ ដំណើរការពិនិត្យតាមដានទាំងមូលក៏ត្រូវបានកំណត់ជាវដ្តពិនិត្យតាមដានសិទ្ធិមនុស្សផងដែរ (សូមមើលផ្នែកខាងក្រោម)។

**វដ្តពិនិត្យតាមដាន**




**ការពិនិត្យតាមដានភាពអាចទទួលបានព័ត៌មាន និងឯកសារនៅមណ្ឌលបោះឆ្នោតក្នុងទីក្រុងហុងកុង**

ប្រទេសចិន រួមទាំង ហុងកុង ត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនពិការ (CRPD) កាលពីខែ កញ្ញា ឆ្នាំ 2012។ ក្រុមស្វ័យតស៊ូមតិមកពីអង្គការ Chosen Power បានចូលរួមក្នុងកិច្ចប្រជុំលើកទី 7 និងទី 8 របស់ CRPD ដើម្បីស្វែងយល់ពីរបៀបដែលរដ្ឋាភិបាលកំពុងគាំទ្រសិទ្ធិរបស់ពួកគេ និងប្រើប្រាស់បទពិសោធន៍នេះក្នុងសកម្មភាពតស៊ូមតិរបស់ខ្លួននៅទីក្រុងហុងកុង។ អង្គការ Chosen Power គឺជាអង្គការស្វ័យតស៊ូមតិ និងជួយខ្លួនឯងទីមួយដែលគ្រប់គ្រងដោយអ្នកដែលមានសមត្ថភាពរៀនសូត្រផ្សេងៗគ្នានៅអាស៊ី ហើយការចូលរួមរបស់ពួកគេក្នុងទីក្រុងហ្សឺណែវបង្ហាញជាលើកដំបូងនូវអ្នកមានពិការភាពផ្នែកប្រាជ្ញាស្មារតី ដែលឡើងថ្លែងនៅចំពោះមុខគណៈកម្មាធិការ។

បន្ទាប់ពីកិច្ចប្រជុំលើកទី 7 ដែលមានការអនុម័តលើបញ្ហានានា អង្គការ Chosen Power បានបញ្ចុះបញ្ចូលឲ្យមានភាពអាចទទួលបានព័ត៌មាន និងឯកសារនៅមណ្ឌលបោះឆ្នោតសម្រាប់អ្នកមានពិការភាពផ្នែកប្រាជ្ញាស្មារតី និងសម្រាប់ផ្តល់សិទ្ធិដល់បុគ្គលគាំទ្រទៅតាមជម្រើសរបស់ខ្លួនក្នុងមណ្ឌលបោះឆ្នោត។ ពួកគេបានជួបជាមួយមន្ត្រីចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតនៅខែ កក្កដា ឆ្នាំ 2012 ដើម្បីបង្ហាញពីបញ្ហារបស់ខ្លួន និងកង្វះលទ្ធភាពរបស់ជនពិការភ្នែកក្នុងការបោះឆ្នោត កង្វះលទ្ធភាពរបស់អ្នកធ្វើការក្នុងស្ថាប័នដើម្បីបោះឆ្នោត និងការពិតដែលមនុស្សដែលកំណត់ថា "មានពិការភាពផ្នែកប្រាជ្ញាស្មារតី" ត្រូវបានដកហូតសិទ្ធិបោះឆ្នោត។

ការបោះឆ្នោតបានធ្វើឡើងនៅខែ កញ្ញា ឆ្នាំ 2012 ហើយអង្គការ Chosen Power បានពិនិត្យតាមដានផ្នែកជាច្រើននៃការបោះឆ្នោត។ ពួករកឃើញថា គេមិនអាចចូលទៅក្នុងគេហទំព័របោះឆ្នោតបាន ពួកគេត្រូវរង់ចាំរយៈពេលយូរដើម្បីទទួលបានការណែនាំស្តីពីការបោះឆ្នោត "ដែលងាយស្រួលអាន" នៅមណ្ឌលបោះឆ្នោត និងជាច្រើនលើកច្រើនសារដែលពួកគេយល់ថា ជំនួយនៅមណ្ឌលបោះឆ្នោតមិនបានគោរពស្វ័យភាព និងការសម្ងាត់របស់ពួកគេបានពេញលេញ។

លទ្ធផលវិជ្ជមានមួយ សម្រាប់ការចូលរួមក្នុងដំណើរការពិនិត្យឡើងវិញរបស់គណៈកម្មាធិការ CRPD គឺការប្រមូលផ្តុំអង្គការជនពិការ និងតួអង្គសង្គមស៊ីវិលដើម្បីចូលរួមជាកម្លាំងផ្តួបដែលជួយបញ្ជ្រាបបញ្ហាពិការភាពទៅក្នុងសង្គមទាំងមូល។ ក្នុងទីក្រុងហុងកុង អង្គការទាំងនេះបានសហការគ្នាដាក់បញ្ហានានាក្នុងទីក្រុងហុងកុង ដែលក្នុងនោះពួកគេបានលើកឡើងពីសិទ្ធិចូលរួមក្នុងនយោបាយដើម្បីបង្កើនសម្ពាធលើរដ្ឋាភិបាលឲ្យធ្វើការផ្លាស់ប្តូរចាំបាច់ សម្រាប់ការចូលរួមដោយស្មើភាពទៅគណៈកម្មាធិការសិទ្ធិមនុស្ស។

## ការប្រើប្រាស់សូចនាករសិទ្ធិមនុស្សដើម្បីពិនិត្យតាមដានការអនុវត្ត

សូចនាករបែបបរិមាណ និងគុណភាពដែលផ្អែកលើវិធីសាស្ត្រហ្មត់ចត់ និងតម្លាភាព អាចយកមកប្រើប្រាស់ក្នុងការពិនិត្យតាមដានការអនុវត្តអនុសាសន៍បាន។ ឧ. សូចនាករផ្ទៀងផ្ទាត់ការអនុវត្តអនុសាសន៍មួយដើម្បីអនុម័តច្បាប់ស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ អាចជាកាលបរិច្ឆេទចាប់ផ្តើមនៃការចូលជាធរមាន និងផ្នែកគ្របដណ្តប់របស់ច្បាប់។

អនុសាសន៍មួយទៀតក្នុងផ្នែកនេះអាចជា "ការបន្តកិច្ចខិតខំប្រឹងប្រែងបង្កើនលទ្ធភាពទទួលបានសេវាពន្យារកំណើតដែលសមស្រប និងមានសុវត្ថិភាពក្នុងប្រទេស"។

សូចនាករមួយស្តីពីសមាមាត្រស្ត្រី ឬដៃគូដែលប្រើប្រាស់មធ្យោបាយពន្យារកំណើតអាចឲ្យភាគីពាក់ព័ន្ធវាយតម្លៃកម្រិតនៃការអនុវត្តបាន។ ទិន្នន័យស្តីពីការប្រើប្រាស់មធ្យោបាយពន្យារកំណើតត្រូវបានបង្កើតឡើងដោយផ្នែកទទួលបន្ទុកប្រជាជនរបស់សហប្រជាជាតិ ដោយប្រើប្រាស់ការអង្កេតតំណាងថ្នាក់ជាតិ។

នៅពេលប្រមូលទិន្នន័យសម្រាប់សូចនាករ ត្រូវមានទិន្នន័យបែងចែកពីគ្នាដើម្បីកំណត់ទិដ្ឋភាពរើសអើងរបស់ស្ថានភាពមួយ។ ក្នុងបញ្ជីមិនលម្អិត និងអាស្រ័យលើអ្វីដែលពាក់ព័ន្ធ និងអាចទៅរួចក្នុងបរិបទនីមួយៗ សូចនាករអាចត្រូវបានបែងចែកទៅតាមជាតិសាសន៍ ពណ៌សំបុរ ភេទ អាយុ ភាសា សាសនា ទស្សនៈនយោបាយ ឬទស្សនៈផ្សេងទៀត ដើមកំណើតសង្គម ឬជាតិ ទ្រព្យសម្បត្តិ ដើមកំណើត ពិការភាពរាងកាយ ឬប្រាជ្ញាស្មារតី ស្ថានភាពសុខភាព (ដូចជា HIV/AIDS) និន្នាការផ្លូវភេទ និងស្ថានភាពពលរដ្ឋ នយោបាយ ឬស្ថានភាពផ្សេងទៀត។ នៅពេលមានការកំណត់សូចនាករពាក់ព័ន្ធ ត្រូវកំណត់ចំណុចដៅដើម្បីបង្ខំឲ្យរដ្ឋប្តេជ្ញា និងអនុវត្តតាមអនុសាសន៍ទាំងនោះ។

អង្គការ Social Watch[6] និង**មជ្ឈមណ្ឌលសិទ្ធិសេដ្ឋកិច្ច និងសង្គម**[7] គឺជាអង្គការដែលមានបទពិសោធន៍ច្រើនក្នុងការប្រើប្រាស់សូចនាករដើម្បីតាមដានបន្តលើអនុសាសន៍[8]។

## 4.6 ការចាប់យកចំណាប់អារម្មណ៍

ការពិនិត្យឡើងវិញលើស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសមួយ ដោយយន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិ ឬការចុះពិនិត្យតាមប្រទេសដោយអ្នកមានអាណត្តិលើនីតិវិធីពិសេស អាចបង្កើតជាចំណាប់អារម្មណ៍ ដូចខាងក្រោម ៖

[6] www.socialwatch.org

[7] www.cesr.org

[8]សម្រាប់ការណែនាំបន្ថែមស្តីពីសូចនាករ សូមមើលសូចនាករសិទ្ធិមនុស្ស ៖ ការណែនាំស្តីពីការវាស់វែង និងការអនុវត្ត (ការបោះពុម្ពផ្សាយរបស់សហប្រជាជាតិ, HR/PUB/12/5)។

- ការយកចិត្តទុកដាក់មិនធ្លាប់មានពីមុនមករបស់ប្រព័ន្ធផ្សព្វផ្សាយ ចំពោះស្ថានភាពសិទ្ធិមនុស្ស
- ចំណុចខ្វះខាតរបស់អាជ្ញាធររដ្ឋក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្សមួយចំនួន នៅថ្នាក់កណ្តាល ឬមូលដ្ឋាន
- គូសន្ទនាថ្មីក្នុងរដ្ឋាភិបាលត្រៀមខ្លួនចូលរួមក្នុងកិច្ចសន្ទនាជាមួយសង្គមស៊ីវិល
- ហេតុផលថ្មីសម្រាប់ការចាត់វិធានការជំរុញសិទ្ធិមនុស្ស
- ការបង្ហាញពីឆន្ទៈនយោបាយនឹងអនុម័តច្បាប់ដែលអនុលោមតាមស្តង់ដាសិទ្ធិមនុស្ស
- ការមានធនធានថ្មីៗដើម្បីធ្វើការក្នុងផ្នែកមួយ និង
- ភាពជាដៃគូ ឬសម្ព័ន្ធដែលត្រូវបានបង្កើតឡើង ឬពង្រឹងសម្រាប់ការពិនិត្យឡើងវិញ។

តួអង្គសង្គមស៊ីវិលអាចដើរតួនាទីសំខាន់ ក្នុងការបង្កើតចំណាប់អារម្មណ៍ជុំវិញសកម្មភាពរបស់យន្តការសិទ្ធិមនុស្ស និងក្នុងការចាប់យកចំណាប់អារម្មណ៍ទាំងនោះ ដើម្បីពន្លឿនយុទ្ធសាស្ត្រសំដៅជំរុញឲ្យមានការការពារសិទ្ធិមនុស្សកាន់តែប្រសើរឡើង។

### 4.7 ការបង្កើត និងសហការជាមួយសម្ព័ន្ធនានា

ការចូលរួមក្នុងការងាររបស់យន្តការសិទ្ធិមនុស្សតាមរយៈក្រុមតួអង្គសង្គមស៊ីវិល តែងផ្តល់ផលវិជ្ជមានដូចខាងក្រោម ៖

- ការដាក់សំណើកាន់តែទូលំទូលាយទៅយន្តការសិទ្ធិមនុស្ស និងលទ្ធភាពខ្ពស់ដែលអនុសាសន៍ឆ្លុះបញ្ចាំងពីអាទិភាពដែលកំណត់ដោយសម្ព័ន្ធ
- ការបែងចែកការងារក្នុងចំណោមអង្គការសមាជិកសម្ព័ន្ធទៅតាមជំនាញ ធនធាន និងឯកទេស ដែលបង្កើតជាការចូលរួម និងការតាមដានបន្តកាន់តែមានប្រសិទ្ធភាព (ឧ. អង្គការមួយចំនួននឹងផ្តោតលើការតស៊ូមតិ ឬការបង្កើនការយល់ដឹង ចំណែកអង្គការផ្សេងទៀតផ្តោតលើការពិនិត្យតាមដាន ការប្រមូល និងការវិភាគទិន្នន័យ ដូចជា ទិន្នន័យបច្ចេកទេស និងព័ត៌មាន។ អង្គការខ្លះផ្តល់ការគាំទ្រដល់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និងជួយផ្សព្វផ្សាយទស្សនៈ និងសក្ខីកម្មរបស់ជនរងគ្រោះ)។
- ទំនាក់ទំនងការងារល្អប្រសើរ កិច្ចសហការ និងសាមគ្គីភាពក្នុងចំណោមតួអង្គសង្គមស៊ីវិល។ នេះជាចំណុចសំខាន់បំផុតនៅពេលតួអង្គសង្គមស៊ីវិលអាចរងការគំរាមកំហែង។

- ការបង្កើនឥទ្ធិពល និងភាពអាចទុកចិត្តបានរបស់សម្ព័ន្ធដោយមានខ្លឹមសារ និងគោលបំណងតែមួយធៀបនឹងយន្តការសិទ្ធិមនុស្ស អាជ្ញាធររបស់រដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀត (ឧ. បេសកកម្មការទូត ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ)
- តួអង្គសង្គមស៊ីវិលតូចៗទាក់ទាញចំណាប់អារម្មណ៍ នៅពេលបញ្ហារបស់ពួកគេត្រូវបានផ្សព្វផ្សាយក្នុងសម្ព័ន្ធ។

**សម្ព័ន្ធតួអង្គសង្គមស៊ីវិលបង្កើតវឌ្ឍនភាពក្នុងការទប់ស្កាត់ការធ្វើទារុណកម្ម តាមរយៈការពិនិត្យឡើងវិញតាមដំណាក់កាលជារួម (UPR) ក្នុងប្រទេសហ្វីលីពីន**

ក្រុម Medical Action Group (MAG) បានចូលរួមក្នុងការរៀបចំរបាយការណ៍រួមរបស់សង្គមស៊ីវិលសម្រាប់ UPR ស្តីពីប្រទេសហ្វីលីពីន។ មុនពេលមាន UPR នៅខែ ឧសភា ឆ្នាំ 2012 សមាជិកសម្ព័ន្ធតួអង្គការសង្គមស៊ីវិលបានរៀបចំបទបង្ហាញសង្ខេបផ្នែកការទូតក្នុងទីក្រុងម៉ានីល ដោយមានការចូលរួមពីស្ថានទូត 20។ ក្នុងទីក្រុងហ្សឺណែវ អង្គការនេះបានរៀបចំកិច្ចប្រជុំជាមួយបេសកកម្មការទូតចំនួន 16 ដើម្បីបង្កើនការយល់ដឹងស្តីពីបញ្ហារបស់ខ្លួន។ សមាជិកសម្ព័ន្ធនិយាយថា "យើងអាចបង្ហាញពីកង្វល់ជាអាទិភាពរបស់យើងក្នុងលក្ខណៈជាក់លាក់ និងច្បាស់លាស់ ដោយចងក្រងព័ត៌មានពិតកម្រាស់មួយទំព័រសម្រាប់បញ្ហានីមួយៗ។ តម្លៃដ៏ធំធេងនៃការធ្វើការក្នុងសម្ព័ន្ធតួអង្គសង្គមស៊ីវិលក្នុងការដាក់របាយការណ៍ និងការបញ្ចុះបញ្ចូលរដ្ឋាភិបាលក្នុងដំណើរការ UPR បានផ្តល់ជាអនុសាសន៍កាន់តែពាក់ព័ន្ធ ហើយវាបានសម្របសម្រួលការតាមដានបន្ត និងការចូលរួមដ៏សកម្មរបស់យើងក្នុងការអនុវត្តរបស់រដ្ឋាភិបាល"។

MAG និងសម្ព័ន្ធរួបរួមប្រឆាំងការធ្វើទារុណកម្ម (UATC) នៅប្រទេសហ្វីលីពីន កំពុងប្រើប្រាស់អនុសាសន៍ UPR ដើម្បីគាំទ្រការងាររបស់ខ្លួនស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម។ តំណាងមួយរូបរបស់ MAG បានសន្និដ្ឋានថា "យើងប្រើប្រាស់អនុសាសន៍ UPR ក្នុងការងារពិនិត្យតាមដាន និងក្នុងសកម្មភាពតស៊ូមតិរបស់យើង ដែលផ្តោតលើការបង្កើនការយល់ដឹងរបស់សាធារណជនស្តីពីផ្នែកទារុណកម្មក្នុងវេជ្ជសាស្ត្រ ដូចជា ការចងក្រងឯកសារដោយផ្អែកលើពិធីសារទីក្រុង Istanbul និងការបង្កើតកម្មវិធីស្តារនីតិសម្បទាសម្រាប់ជនរងគ្រោះនៃការធ្វើទារុណកម្ម និងគ្រួសាររបស់ពួកគេ។ អនុសាសន៍ UPR បានជះឥទ្ធិជាច្រើនលើការកសាងសមត្ថភាពចលនាទប់ស្កាត់ការធ្វើទារុណកម្មក្នុងប្រទេសហ្វីលីពីន"។

**ផែនទីបង្ហាញផ្លូវឆ្ពោះទៅរកការអនុវត្តអនុសាសន៍ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេសស្វីស**

អង្គការ Coalition Suisse Romande sur les droits économiques, sociaux etculturels បានផ្តួចផ្តើមការតាមដានបន្តចំពោះការសង្កេតរួមលើគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រទេសស្វីស។ អង្គការនេះអញ្ជើញតួអង្គសង្គមស៊ីវិលដែលមានជំនាញចម្រុះធ្វើការឆ្លុះបញ្ចាំងលើការសង្កេតរួមដើម្បីជួយពន្យល់ពីកត្តាចាំបាច់ដើម្បីអនុវត្តអនុសាសន៍នីមួយៗ។ ធាតុចូលទាំងអស់ត្រូវបានចងក្រងទៅជាគោលការណ៍ណែនាំជាក់ស្តែងដែលត្រូវបានចែករំលែក និងពិភាក្សាក្នុងកិច្ចពិភាក្សាតុមូលជាមួយមន្ត្រីរដ្ឋាភិបាល។

ខណៈដែលបទពិសោធន៍បង្ហាញថា ការសហការជាមួយសម្ព័ន្ធតែងតែផ្តល់លទ្ធផលល្អប្រសើរ មេរៀនពីមុនបានកំណត់បញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖

- ធនធាន និងពេលវេលាក្នុងការងារសម្របសម្រួល
- ការព្រមព្រៀងលើអាទិភាព និងតួនាទី
- ការរក្សាកម្លាំងចំណាប់អារម្មណ៍ និងស្មារតីរបស់សម្ព័ន្ធ
- ការឯកភាពគ្នាអាចពាក់ព័ន្ធនឹងការលុបចោលបញ្ហាមួយចំនួន។

**ការប្រយុទ្ធប្រឆាំងការរើសអើងពូជសាសន៍ក្នុងប្រទេសជប៉ុន**

បណ្តាញអង្គការមិនមែនរដ្ឋាភិបាលជប៉ុន សម្រាប់ការលុបបំបាត់ការរើសអើងពូជសាសន៍ (ERD Net) ត្រូវបានបង្កើតឡើងនៅឆ្នាំ 2007 ក្រោយដំណើរទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសស្តីពីទម្រង់បច្ចុប្បន្ននៃការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងការមិនអត់អោនពាក់ព័ន្ធនៅឆ្នាំ 2005។ ដោយមានការគាំទ្រពីចលនាអន្តរជាតិប្រឆាំងគ្រប់ទម្រង់នៃការរើសអើង និងការប្រកាន់ពូជសាសន៍ (IMADR) ERD Net បាន និងកំពុងផ្តោតលើការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការប្រកាន់ពូជសាសន៍ (ICERD) ក្នុងប្រទេសជប៉ុន។ ERD Net បានដាក់របាយការណ៍អម (shadow report) ស្តីពីប្រទេសជប៉ុនទៅកាន់គណៈកម្មាធិការលុបបំបាត់ការប្រកាន់ពូជសាសន៍ (CERD)។ នៅខែ កុម្ភៈ ឆ្នាំ 2010 គណៈប្រតិភូ ERD Net បានចូលរួម

ក្នុងកិច្ចប្រជុំ និងរៀបចំបទបង្ហាញសង្ខេបសម្រាប់ CERD។ នៅចន្លោះខែ សីហា ឆ្នាំ 2010 និងខែ មិថុនា ឆ្នាំ 2012 អង្គការនេះបានរៀបចំការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយរដ្ឋាភិបាល និងបាន រៀបចំសិក្ខាសាលាសម្រាប់សមាជិកសភា ដោយផ្អែកលើការសង្កេតរួមរបស់ CERD។ សមាជិកម្នាក់របស់ ERD Net និយាយថា "សកម្មភាពទាំងនេះអាចឲ្យយើងពង្រឹងជំនាញតស៊ូមតិទាំងនៅថ្នាក់សហប្រជាជាតិ និងថ្នាក់ជាតិ។ ក្រៅពីនេះ វាបានជួយសម្របសម្រួលកិច្ចសហការរបស់យើង។ បទពិសោធន៍នេះ ក៏បានផ្តល់លទ្ធភាពឲ្យពួកយើងកំណត់ប្រព័ន្ធផ្សព្វផ្សាយថាជាផ្នែកមួយទៀតដែលយើងចង់ចូលរួមយ៉ាងសកម្ម។ ចំណាប់អារម្មណ៍កាន់តែច្រើនរបស់ប្រព័ន្ធផ្សព្វផ្សាយលើទស្សនៈរបស់យន្តការអន្តរជាតិចំពោះស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសជប៉ុន ពិតជានឹងផ្តល់អត្ថប្រយោជន៍"។

### 4.8 ភាពជាដៃគូ

ការសហការជាមួយដៃគូក្នុងការតាមដានបន្តលើការអនុវត្តសិទ្ធិមនុស្ស អាចផ្តល់គុណតម្លៃជាយុទ្ធសាស្ត្រ។

បទពិសោធន៍កន្លងមកបានបង្ហាញថា ការចូលរួមក្នុងដំណើរការសិទ្ធិមនុស្សរបស់សហប្រជាជាតិ អាចផ្តល់ឱកាសឲ្យមានភាពជាដៃគូថ្មីៗ និងកិច្ចសហការក្នុងចំណោមតួអង្គសង្គមស៊ីវិល។ ការចាប់យកឱកាសទាំងនេះ និងការទាញយកប្រយោជន៍ពីភាពជាដៃគូទាំងនេះ អាចផ្តល់លទ្ធផលកាន់តែច្រើន។ នៅពេលបង្កើតភាពជាដៃគូ ចាំបាច់ត្រូវមានលក្ខណៈចម្រុះដើម្បីធានាថា មានការពិចារណាពីគ្រប់ទស្សនវិស័យទាំងអស់។

ការសហការជាមួយដៃគូអាចកើតឡើងនៅកម្រិតជាច្រើន ៖ ដៃគូខ្លះអាចផ្តល់គោលបំណងតែមួយ ចំណែកដៃគូខ្លះអាចមានធនធាន ជំនាញជាក់លាក់ ឬបណ្តាញទំនាក់ទំនងធំទូលាយ។ ដៃគូផ្សេងទៀតគឺជាអ្នកមានកាតព្វកិច្ចសំខាន់ៗ ឬអាចជះឥទ្ធិពលលើពួកគេ។

ការរៀបចំតួអង្គសំខាន់ៗ និងការចូលរួមចំណែករបស់ពួកគេ រួមទាំងហានិភ័យ និងការគំរាមកំហែង គឺជាមូលដ្ឋានសម្រាប់ការបង្កើតយុទ្ធសាស្ត្រ និងកំណត់តួនាទី។ ក្នុងបញ្ជីមិនលម្អិត តួអង្គសង្គមស៊ីវិលមានបទពិសោធន៍ស្តីពីទម្រង់ផ្សេងៗនៃភាពជាដៃគូ និងកិច្ចសហការជាមួយ ៖

- តួអង្គសង្គមស៊ីវិលនៅកម្រិតផ្សេងៗ និងក្នុងផ្នែកផ្សេងៗ ចាប់ពីអង្គការសហគមន៍រហូតដល់តួអង្គសង្គមស៊ីវិលថ្នាក់ជាតិ និងអន្តរជាតិ
- ម្ចាស់ជំនួយ និងសហគមន៍ការទូត
- ប្រព័ន្ធផ្សព្វផ្សាយ
- សហជីព និងសមាគមវិជ្ជាជីវៈ
- បណ្តាញតាមផ្នែក
- រចនាសម្ព័ន្ធរដ្ឋ ដូចជា រដ្ឋសភា និងគណៈកម្មការរដ្ឋសភាពាក់ព័ន្ធ
- ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ
- អង្គការថ្នាក់តំបន់ និងអន្តរជាតិ ដូចជា អង្គការសហប្រជាជាតិ និងតំណាងតាមមូលដ្ឋានរបស់ OHCHR
- ស្ថាប័នសិក្សាស្រាវជ្រាវ និង
- យន្តការសិទ្ធមនុស្ស។

**កាប្រមូលដៃគូដើម្បីការពារ និងលើកកម្ពស់សិទ្ធិកុមារក្នុងប្រទេសនេប៉ាល់**

ក្នុងប្រទេសនេប៉ាល់ អង្គការ Save the Children បានបណ្តុះបណ្តាលតួអង្គសង្គមស៊ីវិល 138 ស្តីពី UPR។ អង្គការនេះបានគាំទ្រការដាក់សំណើរបស់ភាគីពាក់ព័ន្ធ និងសម្របសម្រួលការតស៊ូមតិនៅថ្នាក់ជាតិ និងអន្តរជាតិ។ ជាលទ្ធផល ឯកសារលទ្ធផលរបស់ UPR មានអនុសាសន៍ 34 ស្តីពីសិទ្ធិកុមារ ហើយអនុសាសន៍ 31 ត្រូវបានទទួលយកដោយរដ្ឋាភិបាលនេប៉ាល់។

អង្គការ Save the Children បានបង្កើតយុទ្ធសាស្រ្តតាមដានបន្តលើ UPR ជុំវិញការប្រមូលភាគីពាក់ព័ន្ធថ្នាក់ជាតិផ្សេងៗ ដូចជា បណ្តាញសង្គមស៊ីវិល គណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិ ស្ថានទូត និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើនភាពម្ចាស់ការថ្នាក់ជាតិនៃដំណើរការ UPR និងពង្រឹងការចូលរួម និងគណនេយ្យភាព។

UPR ពិតជាសំខាន់ក្នុងការប្រមូលផ្តុំតួអង្គសង្គមស៊ីវិលទាំងអស់ក្នុងប្រទេសនេប៉ាល់ជុំវិញរបៀបវារៈសកម្មភាពរួម។ ការរួមបញ្ចូលគ្នានៃកិច្ចប្រជុំកម្រិតខ្ពស់ស្តីពីការតស៊ូមតិជារួម និងទ្វេភាគីជាមួយមន្ត្រីរដ្ឋាភិបាល និងស្ថានទូត និងការបង្កើនការយល់ដឹងតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជា បទសម្ភាសន៍តាមទូរទស្សន៍ និងអត្ថបទសារព័ត៌មានស្តីពី UPR ត្រូវបានយកមកប្រើប្រាស់។ ការ

ផ្សារភ្ជាប់ UPR ទៅនឹងព្រឹត្តិការណ៍ជាក់លាក់ពាក់ព័ន្ធនឹងកុមារ ដូចជា ទិវាសិទ្ធិកុមារ មានប្រសិទ្ធភាពបំផុតក្នុងការបង្កើតចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ។

អង្គការ Save the Children ដែលសហការជាមួយសម្ព័ន្ធសិទ្ធិកុមារថ្នាក់ជាតិ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឲ្យគណៈកម្មការសិទ្ធិមនុស្សថ្នាក់ជាតិរួមបញ្ចូលការពិនិត្យតាមដាន និងតាមដានបន្តលើអនុសាសន៍ UPR ក្នុងអាណត្តិរបស់ខ្លួន។ NHRC មានតួនាទីសំខាន់ក្នុងការធានាភាពអាចរកបាននៃព័ត៌មានផ្លូវការ និងអាចទុកចិត្តបានស្តីពីស្ថានភាពនៃការអនុវត្ត។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលការតាមដានបន្ត អនុសាសន៍ UPR លេខ 108.4 ដែលអំពាវនាវឲ្យមាន "*ការអនុម័តបទប្បញ្ញត្តិគោលនយោបាយស្តីពីសិទ្ធិកុមារដែលត្រូវបានពន្យារពេលជាយូរ ដូចជា ច្បាប់ស្តីពីសិទ្ធិកុមារ បទប្បញ្ញត្តិស្តីពីការអប់រំ គោលនយោបាយការពារកុមារ និងស្តង់ដាអប្បបរមាសម្រាប់មណ្ឌលថែទាំកុមារ*" ត្រូវបានអនុវត្តដោយផ្នែក។ ទាំងគោលនយោបាយស្តីពីកុមារនៅថ្នាក់ជាតិ និងបទដ្ឋានទូលំទូលាយសម្រាប់មណ្ឌលថែទាំកុមារសុទ្ធតែត្រូវបានអនុម័តនៅឆ្នាំ 2012។ ក្រៅពីនេះ គណៈរដ្ឋមន្ត្រីបានអនុម័តលើច្បាប់ស្តីពីសិទ្ធិកុមារ។

ការរៀបចំការងារជាមួយដៃគូអាចបង្ហាញដោយរូបភាព។ ឧ. បទពិសោធន៍ក្នុងប្រទេសនេប៉ាល់ដែលរៀបរាប់ខាងលើអាចបង្ហាញជាក្រាហ្វដូចខាងក្រោម។

**ការប្រមូលដៃគូពាក់ព័ន្ធនឹងសិទ្ធិកុមារក្នុងប្រទេសនេប៉ាល់**




## 4.9 ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹង

ការផ្សព្វផ្សាយ និងការបង្កើនការយល់ដឹងស្តីពីលទ្ធផលរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សសុទ្ធតែជាវិធីមានប្រយោជន៍ក្នុងការជំរុញការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ។

ក្នុងករណីជាច្រើន ការអនុវត្តអាចធ្វើទៅបានដោយសារអ្នកមានសិទ្ធិកាន់តែច្រើន បានដឹង និងទាមទារសិទ្ធិសមស្របរបស់ខ្លួន ឬដោយសារតែអាជ្ញាធរពាក់ព័ន្ធដឹងពីវិធានការដែលពួកគេត្រូវធ្វើដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស។ ការលុបបំបាត់ និងកាត់បន្ថយគម្លាតចំណេះដឹងស្តីពីសិទ្ធិតាមរយៈការបង្កើនការយល់ដឹង និងការផ្សព្វផ្សាយព័ត៌មានសិទ្ធិមនុស្ស ជាវិធីមានប្រសិទ្ធភាពដើម្បីបង្កើនការអនុវត្ត។

ចាប់ពីការបកប្រែទៅជាភាសាក្នុងតំបន់ រហូតដល់ទម្រង់ផ្សេងៗនៃប្រព័ន្ធផ្សព្វផ្សាយ និងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គម តួអង្គសង្គមស៊ីវិលមានភាពឈ្លាសវៃ និងច្នៃប្រឌិតក្នុងការផ្សព្វផ្សាយលទ្ធផលរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស។ លទ្ធភាពរបស់ជនពិការក្នុងការទទួលបានឯកសារ និងព័ត៌មាន គួរត្រូវបានបញ្ចូលទៅក្នុងផែនការផ្សព្វផ្សាយជានិច្ច។

**ការប្រើប្រាស់ "ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន" ដើម្បីផ្សព្វផ្សាយអនុសាសន៍របស់អនុគណៈកម្មាធិការទប់ស្កាត់ការធ្វើទារុណកម្មក្នុងប្រទេសប្រេស៊ីល**

ក្នុងដំណើរទស្សនកិច្ចលើកទី 1 ទៅកាន់ប្រទេសប្រេស៊ីលនៅឆ្នាំ 2011 អនុគណៈកម្មាធិការទប់ស្កាត់ការធ្វើទារុណកម្ម (SPT) បានត្រួតពិនិត្យស្ថានភាពទារុណកម្ម និងការធ្វើទុក្ខបុកម្នេញក្នុងមន្ទីរឃុំឃាំងរបស់ប្រេស៊ីល។ បន្ទាប់មក SPT បានរៀបចំរបាយការណ៍មួយផ្ញើទៅរដ្ឋាភិបាលប្រេស៊ីលដោយផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្នុងប្រទេស។ យោងតាមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងអំពើព្រៃផ្សៃផ្សេងទៀត អំពើអមនុស្សធម៌ ឬការប្រមាថមើលងាយ ឬទណ្ឌកម្ម (OPCAT) របាយការណ៍នេះនឹងត្រូវផ្សព្វផ្សាយជាសាធារណៈប្រសិនបើរដ្ឋាភិបាលសម្រេចចិត្តធ្វើដូច្នេះ។ ទោះបីជាមានសំណើរបស់សង្គមស៊ីវិលក្តី ក៏របាយការណ៍នេះនៅតែរក្សាជាការសម្ងាត់។

នៅខែ ឧសភា ឆ្នាំ 2012 ប្រេស៊ីលបានអនុម័តច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មានសារធារណៈ។ នៅថ្ងៃអនុម័តច្បាប់ Conecta Direitos Humanos (Conectas) បានដាក់សំណើមួយឲ្យរដ្ឋាភិបាលប្រេស៊ីលផ្សព្វផ្សាយរបាយការណ៍របស់ SPT ជាសាធារណៈ។ ក្នុងអំឡុងកាលបរិច្ឆេទដែលកំណត់ដោយច្បាប់នេះ រដ្ឋាភិបាលប្រេស៊ីលបានឆ្លើយតប និងបោះផ្សាយរបាយការណ៍ និងអនុសាសន៍ ដែលរួមមានការបកប្រែជាភាសាព័រទុយហ្គាល់ ក្នុងគេហទំព័ររបស់ក្រសួងសិទ្ធិមនុស្ស។

Conectas យល់ថា ត្រូវតែផ្សព្វផ្សាយរបាយការណ៍របស់ SPT ជាភាសាជាតិ។ ប្រសិនបើគ្មានរបាយការណ៍នេះទេ តួអង្គសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀតមិនអាចពិនិត្យតាមដានការអនុវត្តអនុសាសន៍របស់ SPT បានឡើយ។ Contectas លើកឡើងថា "នេះជាជំហានមួយដ៏សំខាន់ក្នុងការបង្កើនការយល់ដឹងស្តីពីស្ថានភាពដ៏អាក្រក់នៃការធ្វើទារុណកម្មក្នុងប្រទេស។ ដោយយល់ឃើញថា ការបន្តការធ្វើទារុណកម្មក្នុងប្រទេសប្រេស៊ីល គឺជាផលវិបាកដោយផ្ទាល់មួយនៃកង្វះគោលនយោបាយទប់ស្កាត់ និងកង្វះគណនេយ្យភាពសម្រាប់ជនបង្ក ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មានពិតជាមានប្រសិទ្ធភាពក្នុងការធានាថា ការវាយតម្លៃរបស់ SPT ត្រូវបានផ្សព្វផ្សាយ និងអាចប្រើប្រាស់យ៉ាងទូលំទូលាយនៅពេលបច្ចុប្បន្ន ដើម្បីប្រឆាំងនឹងការធ្វើទារុណកម្មដោយភាគីពាក់ព័ន្ធទាំងអស់"។

## ការផ្សព្វផ្សាយតាមអ៊ីនធើរណែតស្តីពីកិច្ចប្រជុំរបស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្មក្នុងប្រទេសអៀរឡង់

នៅឆ្នាំ 2011 ក្រុមប្រឹក្សាសេរីភាពពលរដ្ឋរបស់អៀរឡង់ (ICCL) និង Irish Penal Reform Trust (IPRT) បានរៀបចំរបាយការណ៍អម (shadow report) សម្រាប់ការបង្ហាញជូនជាលើកដំបូងរបស់អៀរឡង់នៅចំពោះមុខគណៈម្មាធិការប្រឆាំងការធ្វើទារុណកម្មរបស់សហប្រជាជាតិ (CAT)។ តាមរយៈក្រុមប្រឹក្សាអន្តរជាតិសម្រាប់ការស្តារនីតិសម្បទាជនរងគ្រោះនៃការធ្វើទារុណកម្ម (IRCTV) ICCL និង IPRT បានរៀបចំការផ្សព្វផ្សាយតាមអ៊ីនធើរណែតជាលើកដំបូងស្តីពីកិច្ចប្រជុំរបស់ CAT ដែលតាមដានដោយតួអង្គសង្គមស៊ីវិល និងស្ថាប័នច្បាប់ជាច្រើនក្នុងប្រទេសអៀរឡង់។

តំណាងមួយរូបរបស់ ICCL បានលើកឡើងថា "យើងបានផ្សព្វផ្សាយរបាយការណ៍អម (shadow report) និងអនុសាសន៍របស់ CAT យ៉ាងទូលំទូលាយ និងទទួលបានការផ្សព្វផ្សាយក្នុងកាសែត និងវិទ្យុធំៗទាំងអស់។ ម៉ោងផ្សាយតាមទូរទស្សន៍ដែលមានអ្នកទស្សនាច្រើនបំផុតបានបង្ហាញពីចាក់ផ្សាយការត្រួតពិនិត្យរបស់អៀរឡង់ ចេញពីការផ្សព្វផ្សាយតាមអ៊ីនធើរណែតរបស់យើង។ នេះជាលើកទីមួយ ដែលសាធារណៈជនអៀរឡង់បានឃើញសន្និសញ្ញាសហប្រជាជាតិជាក់ស្តែង"។

វត្តមានរបស់អៀរឡង់នៅចំពោះមុខ CAT និងការធានាការអនុវត្តតាមអនុសាសន៍ បានចូលរួមចំណែកធ្វើឲ្យមានការផ្លាស់ប្តូរវឌ្ឍនភាពក្នុងប្រទេសអៀរឡង់។ កំណែទម្រង់ពន្ធនាគារមានលក្ខណៈនយោបាយខ្ពស់ ហើយក្រុមពិនិត្យឡើងវិញលើយុទ្ធសាស្ត្រព្រហ្មទណ្ឌ ត្រូវបានបង្កើតឡើង[9]។ គណៈកម្មាធិការនេះបានស្នើឲ្យមានការតាមដានបន្តលើអនុសាសន៍ 4 ក្នុងរយៈពេល 12 ខែ ដូចជា បរាជ័យរបស់រដ្ឋក្នុងការស៊ើបអង្កេតលើការឃុំឃាំងស្ត្រីដោយប្រសិទ្ធភាពក្នុង Magdalene Laundries។ នៅខែ កុម្ភៈ ឆ្នាំ 2013 **របាយការណ៍ផ្លូវការមួយ**ស្តីពីការពាក់ព័ន្ធរបស់រដ្ឋក្នុង Magdalene

---

[9]បង្កើតឡើងដោយក្រសួងយុត្តិធម៌ សមភាព និងការពារ ក្រុមពិនិត្យឡើងវិញលើយុទ្ធសាស្ត្រព្រហ្មទណ្ឌមានអ្នកជំនាញ 12 នាក់ដែលតំណាងឲ្យតុលាការ ប៉ូលីស សេវាសាកល្បង និងមន្ត្រីពន្ធនាគារ។ ក្រុមនេះបានផ្តល់អនុសាសន៍ស្តីពីការលើកកម្ពស់ប្រព័ន្ធព្រហ្មទណ្ឌដែលមានគោលការណ៍ និងនិរន្តរភាព ដូចជា ពាក់ព័ន្ធនឹងកាតព្វកិច្ចអន្តរជាតិរបស់អៀរឡង់។ សម្រាប់ព័ត៌មានបន្ថែមសូមមើល www.justice.ie។

Laundries ត្រូវបានបោះពុម្ពផ្សាយ[10]។ ចាប់ពីពេលនោះមក រដ្ឋបានធ្វើការសូមអភ័យទោសជាសាធារណៈចំពោះស្ត្រី Magdalene និងបានពន្លឿនផែនការផ្តល់សំណង។

**ការផ្សព្វផ្សាយតាមអ៊ីនធើរណែត និងវីដេអូ**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងការពិនិត្យឡើងវិញតាមដំណាក់កាលជារួមត្រូវបានផ្សព្វផ្សាយផ្ទាល់តាមអ៊ីនធើរណែត និងរក្សាទុកដោយ UN web TV[11]។ សង្គមស៊ីវិលអាចថតភាពយន្ត និងផ្សព្វផ្សាយតាមអ៊ីនធើរណែតពីកិច្ចប្រជុំរបស់សន្ធិសញ្ញា។ ក្រុមអង្គការ NGOs ក្នុងទីក្រុងហ្សឺណែវ បានសម្របសម្រួលការផ្សព្វផ្សាយតាមអ៊ីនធើរណែតស្តីពីកិច្ចប្រជុំទាំងអស់របស់សន្ធិសញ្ញា ៖ www.treatybodywebcast.org។

**ខ្សែវីដេអូ**ជាច្រើនដែលផលិតឡើងដោយ OHCHR ត្រូវបានបង្ហោះក្នុងគេហទំព័ររបស់ខ្លួន និងប្រព័ន្ធផ្សព្វផ្សាយសង្គម[12]។

### 4.10 ការតស៊ូមតិ

ការតស៊ូមតិស្តីពីសិទ្ធិមនុស្សអាចត្រូវបានកំណត់ជាទំនាក់ទំនង ដែលសំដៅបង្កើនការអនុវត្តផ្នែកសិទ្ធិមនុស្ស។ ខ្លឹមសារនៃការតស៊ូមតិប្រកបដោយប្រសិទ្ធភាព**ផ្តល់ព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្ស និងក្តីកង្វល់នានា និងសំដៅ**បញ្ចុះបញ្ចូល**ភាគីផ្សេងទៀតឲ្យ**រួមគ្នាចាត់វិធានការ**។

លក្ខណៈពិសេសនៃខ្លឹមសារការតស៊ូមតិស្តីពីសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព ៖

- ផ្អែកលើការពិត និងតួលេខដែលបានផ្ទៀងផ្ទាត់
- មានឧទាហរណ៍ជាក់ស្តែងស្តីពីមនុស្ស
- មានលក្ខណៈសាមញ្ញ និងច្បាស់លាស់
- ប្រើប្រាស់ភាសាសមស្រប (ដោយប្រើប្រាស់កិច្ចសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស ជាជាងវោហាសាស្ត្រនយោបាយ បញ្ចៀសការប្រើភាសាបំពាន)

---

[10]ទាញយករបាយការណ៍តាម ៖ www.justice.ie។

[11]http:webtv.un.org/

[12]ទាញយកខ្សែវីដេអូរបស់ OHCHR តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ៖ www.ohchr.org។

- បញ្ជាក់ដោយនីវសារដែលគួរឲ្យទុកចិត្ត
- មានការអំពាវនាវឲ្យចាត់វិធានការច្បាស់លាស់
- សម្របសម្រួលសម្រាប់ក្រុមគោលដៅ
- ព្យាករពីទឡ្ហីករណ៍ប្រឆាំង។

លទ្ធផលរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សបំពេញចំណុចជាច្រើននៃលក្ខណៈពិសេសទាំងនេះ។ តួអង្គសង្គមស៊ីវិលបានកំណត់ និងផ្តោតអាទិភាពលើលទ្ធផលរកឃើញ និងអនុសាសន៍ដើម្បីធ្វើឲ្យការតស៊ូមតិរបស់ខ្លួនកាន់តែមានប្រសិទ្ធភាព។

**ការតស៊ូមតិ ការបង្កើនការយល់ដឹង និងការពិនិត្យតាមដានការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោតនៅប្រទេសទុយនីស៊ី**

ការសង្កេតរួមរបស់ CRPD នៅឆ្នាំ 2011 ស្តីពីប្រទេសទុយនីស៊ី បានរួមបញ្ចូលអនុសាសន៍ជាច្រើនស្តីពីកំណែទម្រង់ប្រជាធិបតេយ្យរបស់ប្រទេស និងផ្តោតលើការធានាថា ជនពិការត្រូវបានរួមបញ្ចូលក្នុងសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មី និងអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោត និងការចូលរួមក្នុងជីវិតនយោបាយដោយស្មើភាព។

អង្គការលើកកម្ពស់សិទ្ធិជនពិការទុយនីស៊ី (Organisation tunisienne de defense des droits des personnes handicapee-OTDDHP) ដែលជាអង្គការជនពិការមួយដែលត្រូវបានបង្កើតឡើងក្រោយបដិវត្តន៍ រៀបចំសិក្ខាសាលាបង្កើនការយល់ដឹងជច្រើនក្នុងតំបន់ផ្សេងៗសំដៅជំរុញឲ្យជនពិការចូលរួមក្នុងការបោះឆ្នោតនៅពេលខាងមុខ។ សមាជិកភាគច្រើនគឺជាមន្ត្រីអង្កេតការបោះឆ្នោតដែលអនុញ្ញាតឲ្យ OTDDPH ធ្វើការអង្កេតដោយផ្ទាល់លើមណ្ឌលបោះឆ្នោតជាង 100 ក្នុងប្រទេសសំដៅវាយតម្លៃការគោរពស្តង់ដានៃភាពអាចទទួលបាន និងវាស់វែងការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោត។

បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកសភាជាតិ ដែលត្រូវព្រាងរដ្ឋធម្មនុញថ្មីរបស់ទុយនីស៊ី OTDDHP បាន និងកំពុងចាត់វិធានការតស៊ូមតិជាមួយសភាធម្មនុញ្ញដើម្បីធានាការរួមបញ្ចូលសិទ្ធិរបស់ជនពិការទៅក្នុងរដ្ឋធម្មនុញ្ញ។ ដោយផ្អែកការតស៊ូមតិរបស់ពួកគេលើអនុសាសន៍របស់ CRPD និងអនុសាសន៍របស់គណៈកម្មាធិការ CRPD OTDDPH បានថ្លែងក្នុងសវនាការរបស់គណៈកម្មាធិការជាមួយសភា ដែលចូលរួមដោយសមាជិកគណៈកម្មាធិការ និងបានព្រាងបទប្បញ្ញត្តិ

ថ្មីមួយសម្រាប់ការរួមបញ្ចូលជនពិការទៅក្នុងរដ្ឋធម្មនុញ្ញ។

**ការតស៊ូមតិឲ្យមានតុលាការឯករាជ្យក្នុងប្រទេសក្វាតេម៉ាឡា**

អ្នករាយការណ៍ពិសេសស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី បានចុះទៅកាន់ប្រទេសក្វាតេម៉ាឡាក្នុងអំឡុងពេលបោះឆ្នោតតុលាការកំពូល។ ក្នុងដំណើរការបោះឆ្នោតជ្រើសរើសអង្គអយ្យការដែលធ្វើឡើងបន្ទាប់ពីការបោះឆ្នោតជ្រើសរើសចៅក្រម និងជាផ្នែកមួយនៃការងារតស៊ូមតិរបស់ខ្លួន សង្គមស៊ីវិលបានសំអាងជាច្រើនលើរបាយការណ៍របស់អ្នករាយការណ៍ពិសេស ជាពិសេសពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវសម្រាប់ឯករាជ្យភាព តម្លាភាព និងឧត្តមភាពវិជ្ជាជីវៈ។ ការិយាល័យរបស់ OHCHR ប្រចាំប្រទេសក្វាតេម៉ាឡា បានជួយចងក្រងស្តង់ដារអន្តរជាតិដែលអាចអនុវត្តបាន រួមទាំងអនុសាសន៍របស់អ្នករាយការណ៍ពិសេស។ តួអង្គសង្គមស៊ីវិលបានប្រើប្រាស់ការចងក្រងនេះដើម្បីពង្រឹងការតស៊ូមតិរបស់ខ្លួនជាមួយនឹងការជ្រើសរើសគណៈកម្មការ ដើម្បីឲ្យពួកគេស្នើបេក្ខភាពដែលមានគុណវុឌ្ឍិបំផុតសម្រាប់មុខតំណែងអង្គអយ្យការ។ ក្រៅពីនេះ តួអង្គសង្គមស៊ីវិលបានប្រើប្រាស់អនុសាសន៍ទាំងនេះក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ ដែលសំដៅធ្វើឲ្យមានការផ្លាស់ប្តូរលើច្បាប់ និងគណនេយ្យភាពកាន់តែច្រើនពីអាជ្ញាធរពាក់ព័ន្ធនឹងឯករាជ្យភាពរបស់តុលាការ។

**4.11 ការកសាង និងពង្រឹងសមត្ថភាព**

លទ្ធផលរកឃើញ និងអនុសាសន៍របស់យន្តការសិទ្ធិមនុស្ស អាចផ្តោតលើកង្វះសមត្ថភាពជាច្រើនរបស់អាជ្ញាធររដ្ឋ ឬតួអង្គសង្គមស៊ីវិល ដែលរិតត្បិតសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តសិទ្ធិមនុស្ស។ ជាញឹកញាប់ អនុសាសន៍មិនត្រឹមតែកំណត់ចំណុចខ្វះខាតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញឲ្យមានសកម្មភាពកសាងសមត្ថភាពដើម្បីដោះស្រាយបញ្ហាទាំងនេះទៀតផង។ ក្នុងករណីខ្លះ តួអង្គសង្គមស៊ីវិលអាចមានតួនាទីល្អបំផុតក្នុងការលុបបំបាត់គម្លាតទាំងនោះ និងអាចមានបទពិសោធន៍ និងជំនាញផ្នែកការបណ្តុះបណ្តាលសិទ្ធិមនុស្សសម្រាប់តួអង្គសង្គមស៊ីវិល និងអាជ្ញាធររដ្ឋ។

អនុសាសន៍អាចឆ្លុះបញ្ចាំងពីចំណុចខ្វះខាតដែលបានលើកឡើងរួចមកហើយ តាមរយៈសកម្មភាពកសាងសមត្ថភាពដែលអនុវត្តដោយតួអង្គសង្គមស៊ីវិល។ ក្នុងករណីទាំងនេះ អនុសាសន៍ពង្រឹងពី

សារៈសំខាន់នៃសកម្មភាពរបស់សង្គមស៊ីវិល និងតួនាទីរបស់សង្គមស៊ីវិលក្នុងការកសាងសមត្ថភាព។ ក្នុងករណីផ្សេងទៀត អនុសាសន៍អាចផ្ដោតលើចំណុចខ្វះខាតដែលមិនត្រូវបានលើកឡើងក្នុងកម្មវិធីមានស្រាប់។ សង្គមស៊ីវិលដែលចូលរួមក្នុងការតាមដានបន្តនឹងវាយតម្លៃលទ្ធភាពនៃសកម្មភាពកសាងសមត្ថភាពបន្ថែមទៀតតាមរយៈ៖

- ការវាយតម្លៃថាតើតួអង្គសង្គមស៊ីវិល សមស្របក្នុងការផ្ដល់សកម្មភាពកសាងសមត្ថភាពពាក់ព័ន្ធនឹងជំនាញចាំបាច់ ធនធានដែលមាន និងផលប៉ះពាល់រំពឹងទុក ឬទេ។ ការវិភាគពីរបៀបដែលសកម្មភាពកសាងសមត្ថភាពថ្មីៗស៊ីសង្វាក់គ្នានឹងអាទិភាព និងផែនការការងាររបស់តួអង្គសង្គមស៊ីវិល បង្កើតបានជាផ្នែកនៃការវាយតម្លៃនេះ
- ការវាយតម្លៃតម្រូវការរបស់ស្ថាប័ន និងអង្គការគោលដៅ ដូចជា ឆន្ទៈរបស់ពួកគេ ក្នុងការដោះស្រាយបញ្ហាកង្វះសមត្ថភាពដើម្បីបង្កើនការអនុវត្តសិទ្ធិមនុស្ស និង
- ការវិភាគការបំពេញបន្ថែមនឹងកម្មវិធីកសាងសមត្ថភាពផ្សេងទៀត តម្លៃបន្ថែមនៃសកម្មភាពថ្មីៗ ផលប៉ះពាល់ និងនិរន្តរភាព។

បទពិសោធន៍បានបង្ហាញថា អាជ្ញាធររដ្ឋ និងតួអង្គសង្គមស៊ីវិល តែងតែទទួលយកកម្មវិធីកសាងសមត្ថភាព ប៉ុន្តែការណ៍នេះមិនបានផ្ដល់លទ្ធផលរំពឹងទុកដោយស្វ័យប្រវត្តិឡើយ។ ឧបសគ្គអាចកើតចេញពីកង្វះឆន្ទៈក្នុងការផ្លាស់ប្ដូរ ការផ្លាស់ប្ដូរកម្រិតខ្ពស់ក្នុងចំណោមអ្នកទទួលផល កង្វះការរៀបចំសកម្មភាពកសាងសមត្ថភាព (ឧ. គ្មាននិរន្តរភាព គោលបំណងមិនច្បាស់ អ្នកទទួលផលដែលមានកម្រិតចំណេះដឹងផ្សេងគ្នា) ឬកត្តាទាំងអស់នេះ។ ហានិភ័យទាំងនេះត្រូវបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្នក្នុងការរៀបចំកម្មវិធីកសាងសមត្ថភាព និងការវាស់វែងផលប៉ះពាល់នៅពេលវាយតម្លៃលទ្ធផល[13]។

[13]សម្រាប់ការណែនាំស្ដីពីការវាយតម្លៃការបណ្ដុះបណ្ដាលស្ដីពីសិទ្ធិមនុស្ស សូមមើល*ការវាយតម្លៃសកម្មភាពបណ្ដុះបណ្ដាលស្ដីពីសិទ្ធិមនុស្ស* (ការបោះពុម្ពផ្សាយរបស់សហប្រជាជាតិ, HR/P/PT/18)។

**ការផ្តល់ការយល់ដឹង និងការកសាងសមត្ថភាពរបស់កងកម្លាំងសន្តិសុខដើម្បីប្រឆាំងនឹងអំពើហិង្សាផ្លូវភេទក្នុងប្រទេសកូឌីវ័រ**

បន្ទាប់ពី UPR លើប្រទេសកូឌីវ័រនៅឆ្នាំ 2009 អង្គការ NGO SOS Exclusion បានប្រើប្រាស់អនុសាសន៍ទាំងនេះដើម្បីបង្កើតផែនការសកម្មភាព ដោយផ្តោតចម្បងលើការកសាងសមត្ថភាពស្តីពីសិទ្ធិមនុស្សសម្រាប់ប៉ូលីស និងកងទ័ព។ ប្រធានអង្គការនេះបានពន្យល់ថា "យើងបានរៀបចំសិក្ខាសាលា 2 ៖ អនុសាសន៍ UPR ស្តីពីសិទ្ធិស្ត្រី។ វាជាឱកាសមួយក្នុងការវាយតម្លៃស្ថានភាពនៃការអនុវត្តអនុសាសន៍ទាំងនោះជាមួយតួអង្គសំខាន់ៗមួយចំនួន ដូចជា ក្រសួងសាមគ្គីភាព គ្រួសារ ស្ត្រី និងកុមារ ក្រសួងយុត្តិធម៌ និងអង្គការ UN Women"។ បន្ទាប់ពីសកម្មភាពនេះគឺយុទ្ធនាការប្រមូលសង្គមប្រឆាំងអំពើហិង្សាផ្លូវភេទ ដែលជាអនុសាសន៍មួយនៃអនុសាសន៍ UPR។ "យុទ្ធនាការនេះផ្តល់ឱកាសឲ្យពួកយើងប្រមូលផ្តុំតួអង្គសង្គមស៊ីវិល មេដឹកនាំសាសនា ក្រសួងសាមគ្គី និងក្រសួងយុត្តិធម៌ និងសហគមន៍ដែលមានការធ្វើយុទ្ធនាការនេះ"។

### 4.12 ការបញ្ចូលទស្សនវិស័យយេនឌ័រទៅក្នុងសកម្មភាពតាមដានបន្ត

សំណួរខាងក្រោមអាចជួយរួមបញ្ចូលយេនឌ័រនៅពេល**កំណត់អាទិភាព**សកម្មភាពតាមដានបន្តៈ

- តើអនុសាសន៍ជាអាទិភាព និងសកម្មភាពតាមដានបន្តពាក់ព័ន្ធ ជះឥទ្ធិពលភាគច្រើនលើស្ត្រី និង/ឬ បុរស ឬទេ?
- តើទស្សនវិស័យយេនឌ័រត្រូវបានរួមបញ្ចូលក្នុងអន្តរាគមន៍អាទិភាពដោយរបៀបណា? តាមរយៈសកម្មភាពជាក់លាក់តាមយេនឌ័រ និង/ឬ តាមរយៈការបញ្ជ្រាបយេនឌ័រ?
- តើអ្នកមានសិទ្ធិមួយចំនួនប្រឈមនឹងការរើសអើងចម្រុះ ឬទេ? តើសកម្មភាពតាមដានបន្តនឹងលើកឡើងពីស្ថានភាពទាំងនេះ ឬទេ?
- តើសកម្មភាពគ្រោងកំពុងផ្តោតលើការបង្កើនភាពអង់អាចរបស់អ្នកមានសិទ្ធិ និងប្រឆាំងនឹងការរើសអើងយេនឌ័រ និងវិសមភាព ឬទេ?
- តើអ្នកមានសិទ្ធិចម្រុះត្រូវបានពិគ្រោះយោបល់ដើម្បីកំណត់អាទិភាពអន្តរាគមន៍ ឬទេ?

នៅពេល**អនុវត្ត**សកម្មភាពតាមដានបន្ត ៖

- ប្រមូល និងរាយការទិន្នន័យបែងចែកតាមភេទ និងសមាសធាតុផ្សេងទៀត ដូចជា អាយុ ជាតិពន្ធុ ពិការភាព ស្ថានភាពសេដ្ឋកិច្ចសង្គម។ល។
- នៅពេលមិនមានព័ត៌មានយេនឌ័រ ទទួលស្គាល់ចំណុចខ្វះខាតក្នុងការរាយការណ៍
- នៅពេលរៀបចំព្រឹត្តិការណ៍នានា ការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាព ធានាតុល្យភាពយេនឌ័រក្នុងការចូលរួម និងក្នុងចំណោមគ្រូឧទ្ទេស ឬគ្រូឧទ្ទេស បរិយាកាស ដែលគិតគូរពីយេនឌ័រ (ទីកន្លែង រយៈពេលកំណត់) ខ្លឹមសារ និងវិធីសាស្ត្រដែលគិតគូរពី យេនឌ័រ
- ធ្វើការវិភាគយេនឌ័រជាប្រព័ន្ធ
- សហការជាមួយដៃគូដែលគិតគូរពីយេនឌ័រ
- ក្នុងការតស៊ូមតិ និងសកម្មភាពបង្កើនការយល់ដឹង រួមបញ្ចូលខ្លឹមសារស្តីពីសមភាពយេនឌ័រ និងប្រើប្រាស់ភាសា និងរូបភាពដែលគិតគូរពីយេនឌ័រ។

### 4.13 ការឆ្លុះបញ្ចាំងលើការរួមបញ្ចូល ភាពចម្រុះ និងភាពអាចទទួលបាន

នៅពេលរៀបចំផែនការ និងអនុវត្តសកម្មភាពតាមដានបន្ត ៖

- ត្រូវមានលក្ខណៈរួមបញ្ចូលដោយមានការចូលរួមពីភាគីពាក់ព័ន្ធចម្រុះ
- ធានាថា មានការផ្តល់ និងឆ្លុះបញ្ចាំងទស្សនវិស័យចម្រុះក្នុងសកម្មភាពតាមដានបន្ត
- ពិចារណាពីភាពអាចទទួលបានសម្រាប់ការចូលរួមរបស់អ្នកដែលមានសាវតាចម្រុះ ដូចជា ជនជាតិដើម និងជនពិការ និងចាត់វិធានការចងក្រងឯកសារ និងធនធានដែលជនពិការ អាចទទួលបាន។

### 4.14 ការប្រើប្រាស់អនុសាសន៍ក្នុងសកម្មភាពតុលាការ និងបណ្តឹង

តួអង្គសង្គមស៊ីវិលជាច្រើនបានគាំទ្របុគ្គល និងក្រុមដែលទាមទារសិទ្ធិរបស់ខ្លួនតាមរយៈ យន្តការតុលាការ ឬយន្តការដែលមានអំណាចជាតុលាការនៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ ចំណុចនេះអាចរួមបញ្ចូលជំនួយផ្នែកច្បាប់ក្នុងការដាក់បណ្តឹង ទស្សនៈផ្នែកច្បាប់ជំនាញ ការកសាង សមត្ថភាពរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីអនុវត្តច្បាប់ក្នុងការអនុវត្តច្បាប់ស្តីពីសិទ្ធិមនុស្ស ឬជំរុញឲ្យមានការប្រើប្រាស់ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិដោយសកម្មជន និងតុលាការ។

ការប្រើប្រាស់ និងជំរុញការប្រើប្រាស់ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិក្នុងដំណើរការតុលាការនៅ ថ្នាក់ជាតិ និងតំបន់ អាចពង្រឹងយុត្តាធិការសិទ្ធិមនុស្ស។ ការបកស្រាយបទប្បញ្ញត្តិសន្ធិសញ្ញាដែល

មានចែងក្នុងមតិរួមរបស់សន្ធិសញ្ញា អាចបង្ហាញពីធាតុផ្សំពាក់ព័ន្ធនឹងសិទ្ធិ និងអាចពិចារណាដោយតុលាការជាតិក្នុងពេលសម្រេចបណ្តឹង។ ទន្ទឹមនឹងនេះ ការសំអាងលើអនុសាសន៍ជាក់លាក់ដោយយន្តការសិទ្ធិមនុស្សអាចពង្រឹងការទាមទាររបស់អ្នកមានសិទ្ធិ។

**ការទាមទារលទ្ធភាពទទួលបានឱសថទូទៅក្នុងប្រទេសកេនយ៉ា**

នៅថ្ងៃទី 20 ខែ មេសា ឆ្នាំ 2012 សាលដីកាតុលាការជាន់ខ្ពស់របស់ប្រទេសកេនយ៉ាបានគ្របដណ្តប់លើផ្នែកនានានៃច្បាប់ប្រឆាំងការក្លែងបន្លំឆ្នាំ 2008 មិនអនុវត្តចំពោះឱសថទូទៅ ដែលការពារលទ្ធភាពទទួលបានការព្យាបាលសមស្របឡើយ។ បណ្តឹងនេះត្រូវបានធ្វើឡើងដោយអ្នកផ្ទុកមេរោគអេដស៍ 3 នាក់។ KELIN ដែលជាអង្គការសិទ្ធិមនុស្សដែលផ្តោតលើការការពារ និងបង្កើនសិទ្ធិមនុស្សពាក់ព័ន្ធនឹងមេរោគអេដស៍ក្នុងអាហ្វ្រិចបូព៌ា បានផ្តល់ការគាំទ្រដល់ការស្រាវជ្រាវដើម្បីបង្ហាញផ្លូវដល់មេធាវីរបស់កូនក្តី។ ករណីនេះដែលបន្តតាំងពីឆ្នាំ 2009 បានដេញដោលពីទិដ្ឋភាពនៃច្បាប់ប្រឆាំងការក្លែងបន្លំឆ្នាំ 2008 ដែលគំរាមដល់ការនាំចូលឱសថទូទៅ ដូចជា ថ្នាំពន្យារជីវិត (ARVs) សម្រាប់អ្នកផ្ទុកមេរោគអេដស៍។ អ្នករាយការណ៍ពិសេសសហប្រជាជាតិស្តីពីសិទ្ធិទទួលបានសេវាសុខភាព បានដាក់បទបង្ហាញសង្ខេប ដែលបានដកស្រង់ចេញពីសាលក្រម។

ក្នុងសាលក្រមរបស់គាត់ ចៅក្រម Ngugi បានសម្រេចថា កម្មសិទ្ធិបញ្ញាមិនគួររំលោភលើសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានសេវាសុខភាព និងសិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរបស់មនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់កេនយ៉ាឡើយ។ ម្ចាស់ប៉ាតង់នឹងមិនអាចប្រើប្រាស់ច្បាប់នេះដើម្បីបិទការនាំចូលឱសថទូទៅ ដូចដែលអ្នកដាក់បណ្តឹងព្រួយបារម្ភឡើយ[14]។

**4.15 ការចែករំលែកលទ្ធផលនៃសកម្មភាពតាមដានបន្ត និងការអនុវត្តល្អ**

អ្នកមានសិទ្ធិអាចកំណត់ថា ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងយន្តការពាក់ព័ន្ធ ជាអ្វីដែលមិនងាយនឹងសម្រេចបាន។ តើអនុសាសន៍របស់អ្នកជំនាញឯករាជ្យក្នុងទីក្រុងហ្សឺណែវអាចជះឥទ្ធិពលលើជីវិតរបស់ប្រជាជនធម្មតាដោយរបៀបណា? តើវាអាចជះឥទ្ធិពលឲ្យមានការប្រព្រឹត្តល្អប្រសើររបស់អ្នកមានកាតព្វកិច្ចដែលអាចនឹងមិនដឹងពីអ្វីដែលជាសន្ធិសញ្ញា ឬសកម្មភាពរបស់អ្នករាយការណ៍ពិសេស ឬទេ? ប៉ុន្តែការផ្លាស់ប្តូរអាច និងពិតជាកើតឡើងប្រាកដមែន ក្នុងករណីជាច្រើន ដោយសារតែការងារតាមដានបន្តរបស់សង្គមស៊ីវិល។

[14]សូមមើលសាលក្រម ៖ http://bit.ly/L1cEu5 (ដកស្រង់នៅថ្ងៃទី 24 ខែ កក្កដា ឆ្នាំ 2013)។

ការចងក្រងឯកសារ ការចែករំលែក និងការផ្សព្វផ្សាយលទ្ធផលនៃសកម្មភាពតាមដានបន្ត និងការអនុវត្តល្អជំរុញឲ្យភាគីផ្សេងទៀតចូលរួម ចម្លងតាម និងកែសម្រួលបទពិសោធន៍ទៅតាមបរិបទ និងអាទិភាពរបស់ខ្លួន។ យោបល់ត្រឡប់ស្តីពីផលប៉ះពាល់នៃយន្តការសិទ្ធិមនុស្សត្រូវបានវាយតម្លៃខ្ពស់ដោយអ្នកជំនាញដែលធ្វើការក្នុងយន្តការទាំងនេះ។

**ការចែករំលែកធនធាន និងការអនុវត្តស្តីពីបណ្តឹងរឿងក្តីសិទ្ធិមនុស្សពាក់ព័ន្ធនឹងការថែទាំអ្នកជំងឺក្នុងអឺរ៉ុបខាងកើត និងអាស៊ីកណ្តាល**

គម្រោងសិទ្ធិមនុស្សក្នុងការថែទាំអ្នកជំងឺ បានបង្កើតការណែនាំសម្រាប់អ្នកអនុវត្តតាមប្រទេសសម្រាប់មេធាវីដែលចាប់អារម្មណ៍លើបណ្តឹងរឿងក្តីសិទ្ធិមនុស្សជំនួសមុខឲ្យអ្នកជំងឺ។ ការណែនាំនេះមានលក្ខណៈជាក់ស្តែង ដែលគ្របដណ្តប់លើបណ្តឹង និងយន្តការជាជម្រើស ដូចជា មន្ត្រីសាធារណៈ និងស្ថាប័នមានអាជ្ញាប័ណ្ណវេជ្ជសាស្ត្រ និងការពិនិត្យអ្នកជំងឺ និងសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដូចជា ការពិនិត្យឡើងវិញល្អិតល្អន់លើយុត្តាធិការសន្ធិសញ្ញា និងការងាររបស់នីតិវិធីពិសេស។

ក្រៅពីនេះ គម្រោងមានការអនុវត្តក្នុងសហគមន៍ គេហទំព័រសម្រាប់ចែករំលែកឯកសារ និងធនធាន។ ការអនុវត្តក្នុងសហគមន៍មានផ្នែកសំខាន់ៗ 3 ៖ ការបង្រៀនច្បាប់ និងសុខភាព ការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សក្នុងការថែទាំអ្នកជំងឺ និងប្រព័ន្ធផ្សព្វផ្សាយ[15]។

### 4.16 ការចូលរួមក្នុងនីតិវិធីតាមដានបន្តមានស្រាប់ និងការអនុវត្តយន្តការសិទ្ធិមនុស្ស

នីតិវិធីតាមដានបន្ត និងការអនុវត្តរបស់យន្តការសិទ្ធិមនុស្ស ផ្អែកលើកិច្ចសហការរបស់រដ្ឋាភិបាល និងការចូលរួមរបស់អង្គការសង្គមស៊ីវិល។ ផ្នែកខាងក្រោមរបស់សៀវភៅណែនាំរៀបរាប់ពីនីតិវិធីតាមដានបន្តមានស្រាប់ និងការអនុវត្ត។

[15] http://health-rights.org/

## 5. នីតិវិធីតាមដានបន្ត និងការអនុវត្តយន្តការសិទ្ធិមនុស្ស

ការវាយតម្លៃការផ្លាស់ប្តូរក្រោយអនុសាសន៍ស្តីពីសិទ្ធិមនុស្ស ការរៀនសូត្រពីអ្វីដែលបានកើតឡើងក្រោយពេលដែលយន្តការសិទ្ធិមនុស្សចុះពិនិត្យប្រទេសមួយក្រោមនីតិវិធីរបស់ខ្លួន និងការយល់ដឹងពីផលប៉ះពាល់លើមូលដ្ឋានរបស់រចនាសម្ព័ន្ធសិទ្ធិមនុស្សរបស់សហប្រជាជាតិ គឺជាចំណុចស្នូល និងជាគោលបំណងរបស់យន្តការសិទ្ធិមនុស្ស។ ចាប់តាំងពីការបង្កើត យន្តការទាំងអស់ទទួលស្គាល់ថា ភាពពេញលេញផ្អែកលើការផ្លាស់ប្តូរជាវិជ្ជមានដែលពួកគេអាចបង្កើតឡើង ឬជំរុញ។ ភស្តុតាងនៃការផ្លាស់ប្តូរជាវិជ្ជមានគឺភស្តុតាងនៃប្រសិទ្ធិភាពរបស់ពួកគេ។ "ការស្វែងរកភស្តុតាង" នេះបានធ្វើឲ្យមានការបង្កើតទម្រង់ផ្សេងៗនៃការតាមដានបន្ត ដែលយន្តការនីមួយៗបានបង្កើតឡើង។ ការតាមដានបន្តខ្លះត្រូវបានធ្វើឲ្យមានលក្ខណៈផ្លូវការក្នុងនីតិវិធីមានស្រាប់ ដូចជា នីតិវិធីតាមដានបន្តក្នុងការសង្កេតរួមរបស់សន្ធិសញ្ញាជាច្រើន។ ការតាមដានបន្តផ្សេងទៀតគឺជាការអនុវត្តជាទៀងទាត់ ដូចជារបាយការណ៍តាមដានបន្តពីការចុះពិនិត្យតាមប្រទេស ដែលចងក្រងដោយអ្នករាយការណ៍ពិសេសមួយចំនួន។ ក្នុងករណីផ្សេងទៀត ការតាមដានបន្តអាចជាគំនិតផ្តួចផ្តើមបណ្តោះអាសន្ន ដូចជា សិក្ខាសាលាថ្នាក់តំបន់ដើម្បីចែករំលែកបទពិសោធន៍ក្នុងការអនុវត្តអនុសាសន៍ស្តីពីសិទ្ធិមនុស្ស។ ផ្នែកខាងក្រោមរៀបរាប់លម្អិតពីចំណុចទាំងនេះ។

### 5.1 សន្ធិសញ្ញាសិទ្ធិមនុស្ស

#### នីតិវិធីតាមដានបន្តចំពោះការសង្កេតរួម

សន្ធិសញ្ញាបានរៀបចំជាស្រេចនូវនីតិវិធីនានា ដើម្បីជួយដល់រដ្ឋភាគីក្នុងការអនុវត្តអនុសាសន៍ក្នុងការសង្កេតរួម ឬសេចក្តីសម្រេចលើករណីនៃនីតិវិធីបណ្តឹងនីមួយៗ។ សន្ធិសញ្ញាទាំងអស់សុទ្ធតែតម្រូវឲ្យរដ្ឋភាគី លើកឡើងពីការតាមដានបន្តក្នុងរបាយការណ៍តាមដំណាក់កាលរបស់ខ្លួនស្តីពីការអនុវត្ត។ គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម (CAT) គណៈកម្មាធិការលុបបំបាត់ការប្រកាន់ពូជសាសន៍ (CERD) គណៈកម្មាធិការសិទ្ធិមនុស្ស (HRC) គណៈកម្មាធិការលុបបំបាត់ការរើសអើងស្ត្រី (CEDAW) និងគណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ (CED) បានអនុម័តនីតិវិធីតាមដានបន្តផ្លូវការ។ ក្នុងការសង្កេតរួមរបស់ខ្លួន សន្ធិសញ្ញាទាំង 5 បានស្នើឲ្យរដ្ឋរាយការណ៍ក្នុងរយៈពេល 1 ឆ្នាំ (2 ឆ្នាំសម្រាប់ CEDAW) ស្តីពីការចាត់វិធានការឆ្លើយតបនឹងអនុសាសន៍ជាក់លាក់ ឬ "ក្តីកង្វល់អាទិភាព" ដែលអាចអនុវត្តបានយ៉ាងលឿន។ គណៈកម្មាធិការទាំងនេះបានចាត់តាំងអ្នករាយការណ៍

ឬអ្នកសម្របសម្រួលការតាមដានបន្ត ដែលទទួលខុសត្រូវលើការវាយតម្លៃរបាយការណ៍តាមដានបន្តរបស់រដ្ឋភាគី និងបង្ហាញជូនគណៈកម្មាធិការ។ តបតាមការអញ្ជើញ សមាជិកសន្និសញ្ញាខ្លះបានចុះទៅកាន់រដ្ឋភាគីដើម្បីតាមដានបន្តលើរបាយការណ៍ និងការអនុវត្តការសង្កេតរួម។

ពាក់ព័ន្ធនឹងគណៈកម្មាធិការសិទ្ធិមនុស្ស នៅពេលទទួលបានរបាយការណ៍តាមដានបន្តពីរដ្ឋភាគីមួយ អ្នកវាយការណ៍ពិសេសទទួលបន្ទុកការតាមដានបន្ត នឹងរៀបចំរបាយការណ៍វឌ្ឍនភាពក្នុងកិច្ចប្រជុំនីមួយៗ ដែលរួមបញ្ចូលសេចក្តីសង្ខេបរបាយការណ៍តាមដានបន្តរបស់រដ្ឋភាគី និងព័ត៌មានពីអង្គការសង្គមស៊ីវិល និងប្រភពផ្សេងទៀត ព្រមទាំងការវាយតម្លៃរបស់គណៈកម្មាធិការដោយផ្អែកលើលក្ខណវិនិច្ឆ័យការតាមដានបន្តរបស់គណៈកម្មាធិការ (សូមមើលតារាងខាងក្រោម)។ គណៈកម្មធិការបានផ្តល់ព័ត៌មានបន្ថែមទៀតដល់រដ្ឋភាគីស្តីពីសេចក្តីសម្រេចលើរបាយការណ៍តាមដានបន្ត។ ប្រសិនបើរដ្ឋភាគីមួយមិនសហការជាមួយនីតិវិធីតាមដានបន្ត ឬអនុម័តវិធានការដែលគណៈកម្មាធិការយល់ថាមិនទាន់គ្រប់គ្រាន់ អ្នកវាយការណ៍ពិសេសអាចស្នើសុំជួបជាមួយតំណាងរបស់រដ្ឋភាគី។

| លក្ខណវិនិច្ឆ័យវាយតម្លៃការពិនិត្យតាមដានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស |
| --- |
| **ការឆ្លើយតប/វិធានការមានភាពសមស្រប ៖** |
| ក. ការឆ្លើយតបមានលក្ខណៈសមស្របភាគច្រើន |
| **ការឆ្លើយតប/វិធានការមានភាពសមស្របដោយផ្នែក** |
| ខ1. មានការចាត់វិធានការជាក់ស្តែង ប៉ុន្តែត្រូវការព័ត៌មានបន្ថែម |
| ខ2. មានការចាត់វិធានការបឋម ប៉ុន្តែត្រូវការព័ត៌មានបន្ថែម |
| **ការឆ្លើយតប/វិធានការ មិនមានភាពសមស្រប** |
| គ1. ការឆ្លើយតបត្រូវបានទទួល ប៉ុន្តែវិធានការដែលធ្វើឡើងមិនអនុវត្តតាមអនុសាសន៍ |
| គ2. ការឆ្លើយតបត្រូវបានទទួល ប៉ុន្តែមិនពាក់ព័ន្ធនឹងអនុសាសន៍ |
| **គ្មានកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការ** |
| ឃ1. គ្មានការឆ្លើយតបក្នុងកាលបរិច្ឆេទកំណត់ ឬគ្មានការឆ្លើយតបចំពោះសំណួរណាមួយក្នុងរបាយការណ៍ |
| ឃ2. គ្មានការឆ្លើយតបក្រោយការជូនដំណឹង។ |
| **វិធានការដែលធ្វើឡើងផ្ទុយនឹងអនុសាសន៍របស់គណៈកម្មាធិការ** |

ង. ការឆ្លើយតបបង្ហាញថា វិធានការដែលធ្វើឡើងផ្ទុយនឹងអនុសាសន៍របស់គណៈកម្មាធិការ។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

ស្រដៀងគ្នានឹងរបាយការណ៍ "អម" ឬ "បន្ថែម" ដែលដាក់ឲ្យពិចារណាលើរបាយការណ៍របស់រដ្ឋភាគី និងបញ្ហានានា តួអង្គសង្គមស៊ីវិលអាចដាក់បញ្ជូនព័ត៌មានក្នុងក្របខណ្ឌនៃនីតិវិធីតាមដានបន្ត។ ក្នុងករណីនេះ សំណើគួរផ្តោតសំខាន់លើអនុសាសន៍ដែលកំណត់ក្នុងការសង្កេតរួមសម្រាប់នីតិវិធីតាមដានបន្ត និងមានព័ត៌មានច្បាស់លាស់[16] ស្តីពីការចាត់វិធានរបស់អាជ្ញាធរ និងវាយតម្លៃប្រសិទ្ធភាព។ ក្រៅពីនេះ អាចបញ្ជាក់ពីចំណុចបរាជ័យក្នុងការចាត់វិធានការចាំបាច់សម្រាប់ការអនុវត្តអនុសាសន៍។ តួអង្គសង្គមស៊ីវិលអាចនឹងចង់ផ្តល់មតិលើការឆ្លើយតបរបស់រដ្ឋ។ ការស្នើសុំនីតិវិធីតាមដានបន្តដោយតួអង្គសង្គមស៊ីវិល អនុវត្តតាមវិធានតែមួយស្តីពីការសំណើដែលផ្តល់ការពិចារណាលើរបាយការណ៍របស់រដ្ឋភាគី និងបញ្ហានានា និងត្រូវបានផ្សព្វផ្សាយជាសាធារណៈលើគេហទំព័ររបស់ OHCHR ឬរក្សាការសម្ងាត់ ប្រសិនបើវាជាសំណើរបស់អង្គការសាម៉ី។

**ការប្រើប្រាស់ការសង្កេតរួមរបស់ CRC នៅថ្នាក់ជាតិ**

ដើម្បីលើកកម្ពស់វិធីសាស្រ្តទៅវិញទៅមក (cyclical approach) សម្រាប់ការចូលរួមក្នុងដំណើរការរាយការណ៍របស់គណៈកម្មាធិការសិទ្ធិកុមារ (CRC) និងជំរុញឲ្យសង្គមស៊ីវិលប្រើប្រាស់អនុសាសន៍របស់ CRC អស់ពីលទ្ធភាពក្នុងការងារតស៊ូមតិរបស់ខ្លួន អង្គការ Child Rights Connect បានចងក្រងកម្រងករណីសិក្សាជាច្រើនស្តីពីសកម្មភាពតាមដានបន្តរបស់តួអង្គសង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ[17]។

សមាជិកសន្និសញ្ញាអាចចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់ អនុតំបន់ និងថ្នាក់ជាតិស្តីពីការអនុវត្តដែលរៀបចំឡើងដោយសង្គមស៊ីវិល ទីភ្នាក់ងារសហប្រជាជាតិ និង OHCHR ឬរដ្ឋាភិបាល។ សង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងសិក្ខាសាលាទាំងនេះ។

[16] CEDAW ៖ សំណើមិនគួរលើសពីប្រវែង 3,500 ពាក្យឡើយ។

[17] www.childrightsnet.org/NGOGroup/CRC/FollowUp/

### ការចុះតាមដានបន្តរបស់អនុគណៈកម្មាធិការទប់ស្កាត់ការធ្វើទារុណកម្ម

អនុគណៈកម្មាធិការទប់ស្កាត់ការធ្វើទារុណកម្ម (SPT) ដែលបង្កើតឡើងនៅឆ្នាំ 2007 ក្រោមពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម បានចុះស្វែងរកការពិតទៅមន្ទីរឃុំឃាំង និងកន្លែងផ្សេងទៀតដែលរឹតត្បិតសេរីភាពក្នុងដែនដីរបស់រដ្ឋភាគី ដូចជា ប៉ុស្តិ៍ប៉ូលីស ពន្ធនាគារ ស្ថាប័នថែទាំសុខភាពផ្លូវចិត្ត និងសង្គម។ នៅចុងបញ្ចប់នៃការចុះពិនិត្យតាមប្រទេស អនុគណៈកម្មាធិការបានបង្ហាញពីអនុសាសន៍របស់ខ្លួន និងការសង្កេតដល់រដ្ឋនានាតាមរយៈរបាយការណ៍សម្ងាត់។

ប្រសិនបើ SPT យល់ថាមានភាពសមស្រប ខ្លួនអាចស្នើឲ្យមានការចុះតាមដានបន្តរយៈពេលខ្លីក្រោយការចុះពិនិត្យជាទៀងទាត់។ នៅខែ កញ្ញា ឆ្នាំ 2010 SPT បានចុះតាមដានបន្តជាលើកដំបូងក្នុងប្រទេសប៉ារ៉ាហ្គាយ ដែលមានការចូលរួមពីសង្គមស៊ីវិល។

## ការតាមដានបន្តលើសេចក្តីសម្រេចស្តីពីបណ្តឹងនីមួយៗ

ក្នុងកាលៈទេសៈជាក់លាក់ សន្ធិសញ្ញាសិទ្ធិមនុស្សអាចពិចារណាពីបណ្តឹង ឬទំនាក់ទំនងនីមួយៗ[18]។ ក្រោមនីតិវិធីនេះ រាល់បុគ្គលដែលអះអាងថា ក្រោមសន្ធិសញ្ញាជាក់លាក់ សិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន អាចដាក់បណ្តឹងទៅសន្ធិសញ្ញាមួយទល់នឹងរដ្ឋមួយដែលជាភាគីនៃលិខិតុបករណ៍នោះ និងបានទទួលស្គាល់សមត្ថភាពរបស់សន្ធិសញ្ញាដើម្បីពិចារណាពីបណ្តឹងទាំងនោះ។ ដំបូងបណ្តឹងត្រូវបានវាយតម្លៃទៅតាមលក្ខខណ្ឌនៃភាពអាចទទួលយកបាន។ ប្រសិនបើអាចទទួលយកបាន បណ្តឹងនឹងត្រូវបានពិចារណាលើអង្គហេតុ ហើយសន្ធិសញ្ញាអនុម័តសេចក្តីសម្រេចមួយអំពីថាតើ

---

[18]នៅខែ កក្កដា ឆ្នាំ 2013 នីតិវិធីនេះមានក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រី អនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ នីតិវិធីនេះនឹងចូលជាធរមានក្នុងអនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ទាំងអស់ និងសមាជិកគ្រួសាររបស់ពួកគេ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅពេលដែលរដ្ឋភាគីទាំង 10 បានធ្វើសេចក្តីប្រកាសចាំបាច់ក្រោមមាត្រា 77 នៃអនុសញ្ញាទីមួយ និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមចុងក្រោយលើអនុសញ្ញាទីពីរ។

មានការរំលោភលើបទប្បញ្ញត្តិរបស់សន្ធិសញ្ញា ឬទេ។ ប្រសិនបើសន្ធិសញ្ញាសម្រេចថា ដើមបណ្តឹងជាជនរងគ្រោះនៃការរំលោភបំពាន ខ្លួននឹងតម្រូវឲ្យរដ្ឋផ្តល់ព័ត៌មាន ជាទូទៅក្នុងអំឡុងពេល 6 ខែ ស្តីពីជំហានដែលខ្លួនបានធ្វើឡើងដើម្បីអនុលោមតាមសេចក្តីសម្រេចរបស់សន្ធិសញ្ញា។ ការឆ្លើយតបរបស់រដ្ឋត្រូវបានបញ្ជូនទៅដើមបណ្តឹង ដែលអាចផ្តល់ការសង្កេតលើសំណើរបស់រដ្ឋ។

សន្ធិសញ្ញាខ្លះ ជាពិសេសគណៈកម្មាធិការសិទ្ធិមនុស្ស, CAT, CERD និង CEDAW បានបង្កើតនីតិវិធីដើម្បីពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការ។ នីតិវិធីទាំងនេះមានក្នុងការចាត់តាំងអ្នករាយការណ៍ដែលត្រូវតាមដានបន្តលើការអនុវត្តសេចក្តីសម្រេច។ ពួកគេត្រូវបានចាត់តាំងសម្រាប់អំឡុងពេលមួយ ឬក្នុងករណីរបស់ CEDAW ដើម្បីតាមដានបន្តលើករណីជាក់លាក់។ នៅពេលការឆ្លើយតបរបស់រដ្ឋលើការចាត់វិធានការអនុវត្តសេចក្តីសម្រេចមិនទាន់សមស្រប ឬមិនទាន់ធ្វើឡើង អ្នករាយការណ៍ពិសេសអាចពិគ្រោះយោបល់ជាមួយតំណាងការទូតរបស់រដ្ឋភាគី ដែលជាទូទៅ ជាមន្ត្រីការទូតរបស់បេសកកម្មអចិន្ត្រៃយ៍ក្នុងទីក្រុងហ្សឺណែវ ឬញូវយ៉ក។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

ក្នុងករណីដែលតួអង្គសង្គមស៊ីវិលពាក់ព័ន្ធក្នុងបណ្តឹងបុគ្គល (ឧ. ដោយសារតែពួកគេជួយដល់ដើមបណ្តឹងក្នុងការដាក់ញត្តិ) ពួកគេអាចផ្តល់ព័ត៌មានស្តីពីរបៀបអនុវត្តសេចក្តីសម្រេច។

**ការវាយតម្លៃការអនុវត្តសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្ស**

នៅឆ្នាំ 2010 អង្គការ Open Society Justice Initiative បានបោះផ្សាយរបាយការណ៍ "*ពីសាលក្រមឆ្ពោះទៅកេយុត្តិធម៌-ការអនុវត្តសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិ*" ដែលពិនិត្យលើបញ្ហាប្រឈមនៃការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិ ពោលគឺសន្ធិសញ្ញារបស់សហប្រជាជាតិ ប្រព័ន្ធអាហ្វ្រិក ប្រព័ន្ធអឺរ៉ុប និងប្រព័ន្ធអន្តរអាមេរិក។ របាយការណ៍នោះយល់ថា ទោះបីជាមានការសម្រេចបានក្នុងរយៈពេល 25 ឆ្នាំកន្លងមកក៏ដោយ ក៏ប្រព័ន្ធទាំងអស់នេះនៅតែប្រឈមនឹងឧបសគ្គក្នុងការប្រែក្លាយសាលក្រមរបស់ខ្លួនទៅជាការផ្លាស់ប្តូរជាក់ស្តែង។ ក្នុងករណីជាច្រើន សេចក្តីសម្រេចសំខាន់ៗមិនបានផ្តល់កំណែទម្រង់ពេញលេញឡើយ។

នៅពេលវិភាគការអនុវត្តសេចក្តីសម្រេចរបស់សន្ធិសញ្ញា របាយការណ៍នេះរកឃើញថា "ជាទូទៅ ការអនុវត្តដោយជោគជ័យកើតឡើងក្នុងករណីដែលមានលទ្ធភាពនយោបាយខ្ពស់ និងករណី

បណ្តឹងរដ្ឋដែលមានប្រពៃណីនីតិរដ្ឋស្មុគស្មាញ។ ក្នុងករណីដែលមានការអនុវត្ត វាតែងតែធ្វើឡើងដោយសារសង្គមស៊ីវិលរឹងមាំមួយ ដែលអាចបំពេញបន្ថែមលើកិច្ចខិតខំប្រឹងប្រែងតាមដានបន្តរបស់គណៈកម្មាធិការ និងដាក់សម្ពាធក្នុងប្រទេសផ្សេងទៀត"។

5.2 ក្រុមប្រឹក្សាសិទ្ធិមនុស្ស

**ការតាមដានបន្តចំពោះការងាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

សេចក្តីសម្រេចលេខ 60/251 របស់មហាសន្និបាតស្តីពីការបង្កើតក្រុមប្រឹក្សាសិទ្ធិមនុស្ស (ក្រុមប្រឹក្សា) បានសម្រេចថា វិធីធ្វើការរបស់ក្រុមប្រឹក្សានេះត្រូវ**ផ្តល់លទ្ធភាពឲ្យមានការពិភាក្សាពីការតាមដានបន្តលើអនុសាសន៍ និងការអនុវត្តរបស់ខ្លួន**។

ក្រុមប្រឹក្សានេះតាមដានបន្តលើបញ្ហាសិទ្ធិមនុស្សដែលខ្លួនពិភាក្សា ដោយ ៖

- ផ្តល់ការសំអាងជាក់លាក់ស្តីពីការតាមដានបន្តក្នុងសេចក្តីសម្រេច ដែលខ្លួនបានអនុម័ត។ ជាទូទៅ សេចក្តីសម្រេចមានបទប្បញ្ញត្តិដែលកំណត់ថា ក្រុមប្រឹក្សានេះ "នៅតែទទួលបានករណី"។ មានន័យថាប្រធានបទនេះនឹងនៅតែជាចំណុចស្នូលនៃកិច្ចពិភាក្សាក្នុងក្រុមប្រឹក្សានេះក្នុងកិច្ចប្រជុំថ្ងៃខាងមុខទៀត។
- រៀបចំកិច្ចប្រជុំរបស់ខ្លួនជាប្រចាំ និងកិច្ចប្រជុំពិសេសដោយផ្អែកលើចំណុចរបៀបវារៈដែលលេចឡើងជាបន្តបន្ទាប់។ នេះជាកិច្ចប្រជុំជាប្រចាំ ទោះបីជាវាអាចជាកិច្ចប្រជុំពិសេសដែលផ្តោតលើប្រធានបទតែមួយ ឬស្រដៀងគ្នាក៏ដោយ (ឧ. កិច្ចប្រជុំពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសស៊ីរីនៅឆ្នាំ 2011 និង 2012)។
- រៀបចំកិច្ចការយន្តការរបស់ខ្លួន ដូចជា នីតិវិធីពិសេស ឬស្ថាប័នបន្ទាប់បន្សំ ឬ OHCHR ដើម្បីចាត់វិធានការជាក់លាក់ និងរាយការទៅក្រុមប្រឹក្សាក្នុងកិច្ចប្រជុំថ្ងៃខាងមុខ។ ក្រៅពីនេះ ក្រុមប្រឹក្សាអាចសម្រេចបង្កើតយន្តការបណ្តោះអាសន្ន ដូចជា គណៈកម្មការស៊ើបអង្កេត ឬបេសកកម្មស្វែងរកការពិត ដែលមានអាណត្តិស៊ើបអង្កេតលើការរំលោភបំពានសិទ្ធិមនុស្ស និងដាក់របាយការណ៍ដោយមានលទ្ធផលរកឃើញសម្រាប់ដាក់ឲ្យក្រុមប្រឹក្សាពិចារណា។ ជាទូទៅ កិច្ចការផ្សេងទៀតដែលចាត់តាំងដោយក្រុមប្រឹក្សា រួមមាន ការសម្រេចបានការសិក្សា ឬការរៀបចំកិច្ចប្រជុំជំនាញ ឬក្រុមវិនិច្ឆ័យ។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

ទម្រង់តាមដានបន្តដែលមានរៀបរាប់ខាងលើ គឺជាវិធីសាស្ត្រធ្វើការស្តង់ដារបស់ក្រុមប្រឹក្សា។ ទម្រង់សម្រាប់ការចូលរួមរបស់សង្គមស៊ីវិលមានលក្ខណៈដូចគ្នា និងរួមបញ្ចូលលទ្ធភាពសម្រាប់ឲ្យអង្គការ NGOs មានតួនាទីពិគ្រោះយោបល់ ECOSOC ស្តីពីសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ និងការរៀបចំព្រឹត្តិការណ៍បន្ថែម។ អង្គការ NGO ដែលមិនបានធ្វើដំណើរទៅទីក្រុងហ្សឺណែវដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អាចធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់តាមរយៈសារជាវីដេអូសម្រាប់ចំណុចរបៀបវារៈមួយចំនួន។ សម្រាប់ការណែនាំបន្ថែម សូមអានសៀវភៅណែនាំរបស់ OHCHR សម្រាប់សង្គមស៊ីវិល ៖ *ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សរបស់សហប្រជាជាតិ* និងសៀវភៅណែនាំអនុវត្តរបស់ OHCHR សម្រាប់សង្គមស៊ីវិលស្តីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស[19] និងគេហទំព័ររបស់ OHCHR[20]។

ក្រៅពីសេចក្តីថ្លែងការជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ និងព្រឹត្តិការណ៍បន្ថែម វាជាការអនុវត្តស្តង់ដាក្នុងការអញ្ជើញឲ្យសង្គមស៊ីវិលចូលរួមក្នុងការសិក្សា និងកិច្ចប្រជុំជំនាញ និងក្រុមវិនិច្ឆ័យដែលកំណត់អាណត្តិដោយក្រុមប្រឹក្សា។ លើសពីនេះ អង្គការ NGOs អាចចូលរួមក្នុងកិច្ចប្រជុំក្រៅផ្លូវការមិនមានកំណត់ ដែលធ្វើឡើងស្របគ្នានឹងកិច្ចពិភាក្សារបស់ក្រុមប្រឹក្សាលើអត្ថបទពង្រាងសេចក្តីសម្រេច។

ចុងបញ្ចប់ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រដ្ឋក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ ជាថ្មីម្តងទៀត សង្គមស៊ីវិលអាចរៀបចំ កំណត់អាទិភាព និងចាត់វិធានការបង្ខំឲ្យមានការអនុវត្តការប្តេជ្ញាចិត្តស្តីពីសិទ្ធិមនុស្សក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដែលបម្រើឲ្យផលប្រយោជន៍របស់ពួកគេ។

**ស្ថាប័ន យន្តការ និងអាណត្តិបន្ទាប់បន្សំ**

អនុសាសន៍ជាច្រើនត្រូវបានផ្តល់ដោយស្ថាប័ន និងយន្តការបន្ទាប់បន្សំរបស់ក្រុមប្រឹក្សា ដូចជា ៖

➢ ការពិនិត្យឡើងវិញតាមដំណាក់កាលជារួម (សូមមើលផ្នែក 5.4 នៃសៀវភៅណែនាំនេះ)

[19] www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

[20] www.ohchr.org/EN/HRBodies/HRC/Pages/NgoParticipation.aspx

- គណៈកម្មាធិការប្រឹក្សារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
- នីតិវិធីដាក់បណ្ដឹង
- នីតិវិធីពិសេស (សូមមើលផ្នែក 5.3 នៃសៀវភៅណែនាំនេះ)
- វេទិកាសង្គម
- វេទិកាស្ដីពីបញ្ហាជនជាតិភាគតិច
- យន្តការជំនាញស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និង
- វេទិកាស្ដីពីធុរកិច្ច និងសិទ្ធិមនុស្ស

សម្រាប់ការណែនាំស្ដីពីការចូលរួមរបស់សង្គមស៊ីវិលក្នុងស្ថាប័នទាំងនេះ សូមអានសៀវភៅណែនាំរបស់ OHCHR សម្រាប់សង្គមស៊ីវិល ៖ *ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សរបស់សហប្រជាជាតិ* សៀវភៅណែនាំអនុវត្តសម្រាប់សង្គមស៊ីវិលស្ដីពីក្រុមប្រឹក្សាសិទ្ធិមនុស្ស និងសៀវភៅណែនាំអនុវត្តស្ដីពីវេទិកាសង្គម[21]។

**5.3 នីតិវិធីពិសេស**

**តាមដានបន្តលើការចុះពិនិត្យតាមប្រទេស**

អ្នកមានអាណត្តិលើនីតិវិធីពិសេសតម្រូវឲ្យមានការអញ្ជើញដោយរដ្ឋាភិបាល ឲ្យចុះទៅកាន់ប្រទេសសាម៉ី។ នីតិវិធីពិសេសតាមដានបន្តលើ**សំណើសុំឲ្យចុះពិនិត្យ**តាមរយៈ ៖

- ការដាក់សំណើចុះពិនិត្យជាសាធារណៈក្នុងរបាយការណ៍របស់ខ្លួន គេហទំព័រ ក្នុងអំឡុងព្រឹត្តិការណ៍សាធារណៈ និងក្នុងប្រព័ន្ធផ្សព្វផ្សាយ
- ការរៀបចំកិច្ចប្រជុំជាមួយតំណាងការទូតរបស់ប្រទេសពាក់ព័ន្ធ
- ការចុះផ្ទាល់ទៅកាន់ប្រទេស ឬតំបន់ដែលអាចជួយឲ្យមានការអញ្ជើញផ្លូវការ (ឧ. ការចុះសិក្សាស្រាវជ្រាវ។ល។) និង
- ការជូនសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរផ្លូវការស្ដីពីសំណើររបស់ខ្លួន និងការផ្សព្វផ្សាយជាសាធារណៈ។

[21]www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

ក្នុងពេលចុះពិនិត្យ នីតិវិធីពិសេសបានបង្កើតការអនុវត្តស្តីពីការតាមដានបន្តជាច្រើនដូចខាងក្រោម។

1. **ការចុះតាមដានបន្តក្នុងប្រទេស** ៖ អាណត្តិជាច្រើនបានចុះពិនិត្យដើម្បីតាមដានបន្តលើបេសកកម្មក្នុងប្រទេសពីមុន។ ការចុះពិនិត្យទាំងនេះផ្តល់ការវាយតម្លៃហ្មត់ចត់ពីវឌ្ឍនភាព និងឧបសគ្គធៀបនឹងលទ្ធផលរកឃើញ និងអនុសាសន៍នៃការចុះពិនិត្យពីមុន។ យ៉ាងនេះក្តី ការចុះតាមដានបន្តគឺជាការអនុវត្តល្អ ៖ មានការចុះពិនិត្យតិចតួចក្នុងចំណោមការចុះពិនិត្យតាមប្រទេស 40-50/ឆ្នាំ ដែលធ្វើឡើងដោយនីតិវិធីពិសេសគឺជាការចុះតាមដានបន្តដោយសារកង្វះធនធាន។

**ឧទាហរណ៍នៃការចុះពិនិត្យតាមដានបន្តក្នុងប្រទេស**

អ្នករាយការណ៍ពិសេសស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបអាសអាភាសកុមារ ៖

- ✓ ឆ្នាំ 2012 ៖ ប្រទេសហ្គាតេម៉ាឡា (A/HRC/22/54/Add.1)

អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងអំពើឃោរឃៅផ្សេងទៀត អំពើអមនុស្សធម៌ និងការប្រមាថមើលងាយ ឬទណ្ឌកម្ម

- ✓ ឆ្នាំ 2012 ៖ ប្រទេសអ៊ុយរូហ្គាយ (A/HRC/22/53/Add.3)

អ្នករាយការណ៍ពិសេសស្តីពីទម្រង់បច្ចុប្បន្ននៃការប្រកាន់ពូជសាសន៍ ការរើសអើងពូជសាសន៍ ការស្អប់ជនបរទេស និងការមិនអត់អោនពាក់ព័ន្ធ

- ✓ ឆ្នាំ 2011 ៖ ប្រទេសហុងគ្រី (A/HRC/20/33/Add.1)

អ្នករាយការណ៍ពិសេសស្តីពីអំពើហិង្សាលើស្ត្រី បុព្វហេតុ និងផលវិបាក

- ✓ ឆ្នាំ 2011 ៖ សហរដ្ឋអាមេរិក (A/HRC/17/26/Add.5)
- ✓ ឆ្នាំ 2010 ៖ ប្រទេសអែលសាល់វ៉ាឌ័រ (A/HRC/17/26/Add.2) និង ប្រទេសអាល់ហ្សេរី (A/HRC/17/26/Add.3)

អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងការប្រយុទ្ធប្រឆាំងភេរវកម្ម

- ✓ ឆ្នាំ 2011 ៖ ប្រទេសទុយនីស៊ី (A/HRC/16/51/Add.2)

2. **របាយការណ៍តាមដានបន្ត ៖** អាណត្តិជាច្រើនបានបោះពុម្ពរបាយការណ៍តាមដានបន្តដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយរដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សជាតិ និងសង្គមស៊ីវិល។ ការអនុវត្តដ៏គួរឲ្យចាប់អារម្មណ៍នៃរបាយការណ៍តាមដានបន្តលើការចុះពិនិត្យតាមប្រទេស ត្រូវបានបង្កើតឡើងដោយក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម អ្នករាយការណ៍ពិសេសស្តីពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ យ៉ាងរហ័ស និងតាមទំនើងចិត្ត អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្ស និងភាពក្រីក្រធ្ងន់ធ្ងរ និងអ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ។

**របាយការណ៍តាមដានបន្តរបស់ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត**

នៅឆ្នាំ 2010 ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត បានអនុម័តទម្រង់មួយសម្រាប់របាយការណ៍តាមដានបន្តរបស់ខ្លួន រៀបចំកិច្ចពិភាក្សាតុមូលដែលឆ្លុះបញ្ចាំងពីអនុសាសន៍របស់ក្រុមការងារ ការពិពណ៌នាសង្ខេបស្តីពីស្ថានភាពនេះនៅពេលមានការចុះពិនិត្យតាមប្រទេស និងខ្លឹមសារសង្ខេបស្តីពីការចាត់វិធានការដោយផ្អែកលើព័ត៌មានដែលប្រមូលដោយក្រុមការងារ ទាំងពីប្រភពរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល។ ចាប់តាំងពីពេលនោះមក ក្រុមការងារបានចេញរបាយការណ៍តាមដានបន្តស្តីពីវឌ្ឍនភាព និងឧបសគ្គក្នុងស្ថានភាពនៃការបាត់ខ្លួនដោយបង្ខំបន្ទាប់ពីការចុះទៅកាន់ប្រទេសកូឡុំប៊ី អែលសាល់វ៉ាឌ័រ ក្វាតេម៉ាឡា ហុងឌូរ៉ាស ម៉ូរ៉ូកូ និងនេប៉ាល់។

**តារាងតាមដានបន្តរបស់អ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ**

អ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ បញ្ជូនលិខិតតាមដានបន្តក្រោយការចុះពិនិត្យតាមប្រទេសដើម្បីទទួលបានព័ត៌មានថ្មីៗស្តីពីការអនុវត្តអនុសាសន៍នៅថ្នាក់ជាតិ។ តារាងតាមដានបន្តស្តីពីប្រទេសដែលបានចុះពិនិត្យតាំងពីឆ្នាំ 2005 មានសេចក្តីសន្និដ្ឋាន និងអនុសាសន៍ពីរបាយការណ៍ចុះពិនិត្យតាមប្រទេស និងព័ត៌មានតាមដានបន្តពីឯកសារសហប្រជាជាតិពាក់ព័ន្ធ ដូចជា ពីការពិនិត្យឡើងវិញតាមដំណាក់កាលជារួម នីតិវិធីពិសេស និងសន្ធិសញ្ញា[22]។

3. **ព្រឹត្តិការណ៍តាមដានបន្ត ៖** មិនថាដោយមានគំនិតផ្តួចផ្តើមពីនីតិវិធីពិសេស ឬយ៉ាងណានោះទេ រដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សជាតិ សង្គមស៊ីវិល ឬ OHCHR ព្រឹត្តិការណ៍តាមដានបន្តថ្នាក់ជាតិ តំបន់ ឬអន្តរជាតិ សុទ្ធតែអាចផ្តល់ប្រយោជន៍ដល់ការវាយតម្លៃវឌ្ឍនភាព និងចែករំលែកបទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្តអនុសាសន៍ពីការចុះពិនិត្យតាមប្រទេស។ ព្រឹត្តិការណ៍ទាំងនេះអាចមានទម្រង់ជាកិច្ចពិភាក្សាតុមូល កិច្ចប្រជុំជំនាញ ឬសន្និសីទ។

**សិក្ខាសាលាស្តីពីទាសភាពក្នុងប្រទេសម៉ូរីតានី**

នៅខែ មករា ឆ្នាំ 2013 អ្នករាយការណ៍ពិសេសស្តីពីទម្រង់ទាសភាពបច្ចុប្បន្ន បានចូលរួមក្នុងសិក្ខាសាលាតាមដានបន្តស្តីពីការអនុវត្តអនុសាសន៍របស់ខ្លួន បន្ទាប់ពីការចុះពិនិត្យក្នុងប្រទេសម៉ូរីតានី។ មន្ត្រីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលចូលរួមក្នុងសិក្ខាសាលា បានបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តអនុសាសន៍របស់អ្នករាយការណ៍ពិសេស។ ការិយាល័យរបស់ OHCHR ប្រចាំប្រទេសម៉ូរីតានីបានសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីជំរុញឲ្យរដ្ឋាភិបាលអនុម័ត និងអនុវត្តជាផ្លូវការនូវផែនទីបង្ហាញផ្លូវនោះ។

[22] www.ohchr.org/EN/Issues/FreedomReligion/Pages/Visits.aspx

**ការផ្សព្វផ្សាយលទ្ធផលរកឃើញស្តីពីស្ថានភាពរបស់ជនជាតិដើមភាគតិចក្នុងប្រទេសឈីលី និង អាហ្សង់ទីន**

នៅខែ មករា ឆ្នាំ 2010 អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច បានរៀបចំសន្និសីទតាមវីដេអូស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងប្រទេសឈីលី។ សន្និសីទនេះត្រូវបានផ្សព្វផ្សាយដំណាលគ្នាក្នុងទីក្រុងទាំង 5 របស់ឈីលី ដោយមានជំនួយពីតួអង្គសង្គមស៊ីវិល និងការិយាល័យប្រចាំតំបន់អាមេរិកខាងត្បូងរបស់ OHCHR។ ក្នុងបទបង្ហាញរបស់ខ្លួន អ្នករាយការណ៍ពិសេសបានពន្យល់ពីសេក្តីសន្និដ្ឋាន និងការសង្កេតរបស់ខ្លួនដូចមានឆ្លុះបញ្ចាំងក្នុងរបាយការណ៍ថ្នាក់ប្រទេសរបស់គាត់។

នៅឆ្នាំ 2012 អ្នករាយការណ៍ពិសេសបានបន្តចុះទៅប្រទេសអាហ្សង់ទីន ដោយធ្វើសន្និសីទតាមវីដេអូដែលរៀបចំដោយក្រុមប្រចាំប្រទេសរបស់សហប្រជាជាតិ។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

- សំណើរឲ្យចុះពិនិត្យ
  - ស្នើរទៅអ្នកមានអាណត្តិថា ពួកគេស្នើឲ្យមានការចុះទៅកាន់ប្រទេសរបស់ខ្លួន និងផ្តល់ព័ត៌មានជាក់ស្តែងដើម្បីជាសំអាងដល់ការចុះពិនិត្យនោះ
  - ទទួលបានព័ត៌មានស្តីពីសំណើឲ្យចុះពិនិត្យដែលត្រូវបានពន្យារពេល តាមរយៈ អ៊ីម៉ែលសង្គមស៊ីវិលរបស់ OHCHR
  - តស៊ូមតិជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត (ឧ. សមាជិកសភា បេសកកម្មការទូត) ដើម្បីធានាសំណើរឲ្យចុះពិនិត្យ។
- ចូលរួមក្នុងការរៀបចំ និងសម្រេចបានការចុះពិនិត្យតាមដានបន្ត
- ផ្តល់ព័ត៌មានសម្រាប់របាយការណ៍តាមដានបន្ត
- ស្នើ ចូលរួម និងក្នុងករណីចាំបាច់ រៀបចំព្រឹត្តិការណ៍តាមដានបន្ត។

### ការតាមដានបន្តលើទំនាក់ទំនង

របាយការណ៍ទំនាក់ទំនងរួមត្រូវបានដាក់ដោយនីតិវិធីពិសេសទាំងអស់ ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងកិច្ចប្រជុំជាប្រចាំនីមួយៗ។ របាយការណ៍ទំនាក់ទំនងត្រូវបានចេញ 3 ដង/ឆ្នាំ និងរួមបញ្ចូលសេចក្តីសង្ខេបខ្លីស្តីពីបទចោទប្រកាន់ដែលបានបង្ហាញដល់រដ្ឋ ឬអង្គភាពផ្សេងទៀត។ អត្ថបទស្តីពីទំនាក់ទំនងដែលបញ្ជូនទៅ និងការឆ្លើយតបរបស់រដ្ឋាភិបាល អាចទាញយកបានតាម hyperlink។ នីតិវិធីពិសេសអាចទទួល និងពិចារណាពីព័ត៌មានបន្ថែមស្តីពីករណីដែលទំនាក់ទំនងមួយត្រូវបានបញ្ជូន។ ជាទូទៅ ព័ត៌មានបន្ថែមត្រូវបានផ្តល់ដោយប្រភពតែមួយដែលបានផ្តល់ព័ត៌មានបឋម។ នៅឆ្នាំ 2012 នីតិវិធីពិសេសទទួលបានព័ត៌មានបន្ថែមស្តីពីទំនាក់ទំនងក្នុងករណី 21%។

នីតិវិធីពិសេសអាចបញ្ជូនទំនាក់ទំនងតាមដានបន្ត នៅពេលការវិវឌ្ឍនានាបង្កើតបានជាអន្តរាគមន៍ថ្មីមួយ។ ទំនាក់ទំនងតាមដានបន្តជាច្រើន ផ្អែកលើព័ត៌មានបន្ថែមដែលដាក់បញ្ជូន។ ក្នុងឆ្នាំ 2012 ទំនាក់ទំនង 31% គឺជាទំនាក់ទំនងតាមដានបន្ត។

ការតាមដានបន្តលើទំនាក់ទំនងក៏ធ្វើឡើងក្នុងពេលចុះពិនិត្យតាមប្រទេស និងតាមរយៈកិច្ចពិគ្រោះយោបល់ការទូតជាមួយតំណាងរបស់រដ្ឋពាក់ព័ន្ធផងដែរ។ ក្នុងករណីជាតំណាងមួយចំនួនតូច នីតិវិធីពិសេស អាចចេញសេចក្តីប្រកាសព័ត៌មាន។

ការតាមដានបន្តលើទំនាក់ទំនងអាចសម្រេចបាន តាមរយៈការសង្កេតលើរបាយការណ៍ប្រចាំឆ្នាំរបស់អ្នកមានអាណត្តិ។ ការសង្កេតពាក់ព័ន្ធចម្បងនឹងនិន្នាការ និងគំរូនៃការរំលោភបំពានសិទ្ធិមនុស្សក្នុងប្រទេសមួយក្នុងអំឡុងពេលរាយការណ៍ ប៉ុន្តែផ្អែកលើករណីជាច្រើន។

**របាយការណ៍សង្កេតរបស់អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពបង្កើតសមាគម**

ចាប់តាំងពីការចាប់ផ្តើមអាណត្តិរបស់ខ្លួននៅឆ្នាំ 2010 អ្នករាយការណ៍ពិសេសបានចេញរបាយការណ៍សង្កេត 2 ដែលគាត់បានលើកឡើងជាច្រើនលើកច្រើនសារពីបញ្ហាកង្វល់លើករណីរំលោភសិទ្ធិមនុស្សមួយចំនួន ដោយយោងតាមការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះទំនាក់ទំនងនានា។

**មូលដ្ឋានទិន្នន័យរបស់ក្រុមការងារទទួលបន្ទុកការឃុំខ្លួនតាមទំនើងចិត្ត**

បន្ទាប់ពីបានចាប់ផ្តើមនៅឆ្នាំ 2011 **មូលដ្ឋានទិន្នន័យ**របស់ក្រុមការងារទទួលបន្ទុកការឃុំខ្លួនតាមទំនើងចិត្ត គឺជាឧបករណ៍ស្រាវជ្រាវជាក់ស្តែងសម្រាប់ស្រង់មតិយោបល់ដែលអនុម័តដោយក្រុមការងារតាំងពីឆ្នាំ 1991។ **មូលដ្ឋានទិន្នន័យ**នេះសម្របសម្រួលការវិភាគបែបគុណភាព និងបែបបរិមាណលើមតិយោបល់នានា និងអាចជួយដល់ជនរងគ្រោះនៃការឃុំខ្លួនតាមទំនើងចិត្ត អ្នកអនុវត្ត និងបុគ្គលផ្សេងទៀត ក្នុងការដាក់បញ្ជូនករណីចោទប្រកាន់ពីការឃុំខ្លួនតាមទំនើងចិត្តទៅក្រុមការងារ[23]។

**ការតាមដានបន្តលើករណីបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត**

ក្រុមការងារទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្ត ជំរុញឲ្យមានការបង្កើតបណ្តាញទំនាក់ទំនងរវាងគ្រួសារ និងរដ្ឋាភិបាលពាក់ព័ន្ធ។ រាល់ព័ត៌មានបន្ថែមជាក់ស្តែងដែលប្រភពបានស្នើពាក់ព័ន្ធនឹងករណីមិនទាន់ជម្រះមួយ ត្រូវបានបញ្ជូនទៅរដ្ឋាភិបាលពាក់ព័ន្ធ។ រាល់ព័ត៌មានដែលផ្តល់ដោយរដ្ឋាភិបាលពាក់ព័ន្ធស្តីពីករណីជាក់លាក់ត្រូវបានបញ្ជូនទៅប្រភពដើមវិញ។ ក្រុមការងារបញ្ជូនការឆ្លើយតបរបស់រដ្ឋស្តីពីជោគវាសនា ឬការបាត់ដំណឹងរបស់អ្នកបាត់ខ្លួនទៅប្រភព និងស្នើឲ្យប្រភពផ្តល់ការសង្កេត ឬព័ត៌មានលម្អិតបន្ថែម។ ប្រសិនបើប្រភពមិនឆ្លើយតបក្នុងរយៈពេល 6 ខែ ឬប្រសិនបើប្រភពជំទាស់នឹងព័ត៌មានសំអាងរបស់រដ្ឋាភិបាលដែលក្រុមការងារយល់ថា មិនសមហេតុផល ករណីនោះត្រូវចាត់ទុកថា បានបញ្ជាក់។ ករណីនានានៅតែរក្សាទុករហូតទាល់តែមានការបញ្ជាក់ បញ្ឈប់ ឬមានសេចក្តីសម្រេចបិទបញ្ចប់ករណី។ ក្រុមការងារជូនដំណឹងដល់រដ្ឋាភិបាលពាក់ព័ន្ធ ម្តង/ឆ្នាំ ស្តីពីករណីដែលមិនទាន់ត្រូវបានបញ្ជាក់ និង 3 ដង/ឆ្នាំ ស្តីពីករណីបន្ទាន់ទាំងអស់ដែលត្រូវបានបញ្ជូនចាប់តាំងពីកិច្ចប្រជុំពីមុន។ ក្នុងកម្រិតដែលអាចទៅរួច និងយោងតាមសំណើ ក្រុមការងារផ្តល់ដល់រដ្ឋាភិបាលពាក់ព័ន្ធ ឬប្រភពនូវព័ត៌មានបច្ចុប្បន្នភាពស្តីពីករណីមួយចំនួន[24]។

---

[23] www.unwgaddatabase.org/un/

[24] សម្រាប់ព័ត៌មានបន្ថែម សូមមើលវិធីសាស្ត្រធ្វើការដែលត្រូវបានកែសម្រួលឡើងវិញរបស់ក្រុមការងារ (A/HRC/10/9, ឧបសម្ព័ន្ធ 1)។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

- ពិនិត្យរបាយការណ៍ទំនាក់ទំនងជាប្រចាំដើម្បីស្វែងយល់ពីទំនាក់ទំនង ដែលបានបញ្ជូនស្តីពីស្ថានភាព និងករណីសំខាន់ៗ
- ផ្សព្វផ្សាយរបាយការណ៍យ៉ាងទូលំទូលាយក្នុងបណ្តាញមូលដ្ឋាន តំបន់ ជាតិ និងអន្តរជាតិ ដើម្បីប្រមូលព័ត៌មានបន្ថែមស្តីពីករណី
- បញ្ជូនព័ត៌មានដោយមានបច្ចុប្បន្នភាពស្តីពីចំណុចវិវឌ្ឍន៍ជាវិជ្ជមាន ឬវិជ្ជមានពាក់ព័ន្ធនឹងទំនាក់ទំនងពីមុន
- ពិនិត្យឡើងវិញលើការឆ្លើយតបរបស់រដ្ឋាភិបាល និងបញ្ជូនមតិយោបល់ពាក់ព័ន្ធទៅនីតិវិធីពិសេស
- បង្កើតទំនាក់ទំនងជាប្រចាំជាមួយអ្នកមានអាណត្តិនីតិវិធីពិសេស តាមរយៈក្រុមគាំទ្រ OHCHR របស់ខ្លួន និង
- ប្រើប្រាស់អ៊ីម៉ែល urgent-action@ohchr.org ឬអ៊ីម៉ែលទូទៅរបស់អាណត្តិនីតិវិធីពិសេសពាក់ព័ន្ធ។ ចូលទៅកាន់នីតិវិធីពិសេសតាមគេហទំព័រ http://goo.gl/5qoNL។

**ទំនាក់ទំនង និងការតាមដានបន្តលើទំនាក់ទំនងតាមតំបន់ ឆ្នាំ 2012**



### ការតាមដានបន្តលើរបាយការណ៍តាមផ្នែក

សម្រាប់ជាការអនុវត្តស្តង់ដា នីតិវិធីពិសេសរៀបចំ ឬចូលរួមក្នុងព្រឹត្តិការណ៍នានាដើម្បីបង្ហាញ ឬពិភាក្សាពីរបាយការណ៍តាមផ្នែកប្រចាំឆ្នាំរបស់ខ្លួនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ឬមហាសន្និបាត។ ទាំងនេះអាចជាព្រឹត្តិការណ៍បន្ថែមក្នុងអំឡុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ឬសន្និសីទ ឬសិក្ខាសាលាផ្សេងទៀត។ នីតិវិធីពិសេសតែងចេញសេចក្តីប្រកាសព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានតាមគេហទំព័រ និងរៀបចំសន្និសីទសារព័ត៌មានស្តីពីប្រធានបទរបាយការណ៍។ ទិវាអន្តរជាតិតាមផ្នែក អាចជាឱកាសសម្រាប់ការទាក់ទងចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយស្តីពីបញ្ហាសិទ្ធិមនុស្ស ដែលបានលើកឡើងក្នុងរបាយការណ៍តាមផ្នែក។

**ឧបករណ៍តាមគេហទំព័រ ៖ អត្ថបទដកស្រង់ស្តីពីសេរីភាពសាសនា ឬជំនឿ និងគំនិតផ្តួចផ្តើមប្រឆាំងការធ្វើទារុណកម្ម**

**អត្ថបទដកស្រង់ស្តីពីសេរីភាពសាសនា ឬជំនឿ**

ឆ្នាំ 2011 គឺជាខួបទី 25 ឆ្នាំនៃការបង្កើតអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីសេរីភាពសាសនា ឬជំនឿ។ ក្នុងឱកាសនេះ **អត្ថបទដកស្រង់ស្តីពីសេរីភាពសាសនា ឬជំនឿ** ត្រូវបានបង្ហាញឡើងដោយមានការសង្កេត និងអនុសាសន៍របស់អ្នកមានអាណត្តិ 4 នាក់ដែលបានបម្រើការងារនេះតាំងពីឆ្នាំ 1986។ ដោយត្រូវបានរៀបចំជាឧបករណ៍សម្រាប់ការតស៊ូមតិ ការអប់រំ និងការស្រាវជ្រាវ អត្ថបទដកស្រង់នេះរួមបញ្ចូលខ្លឹមសារដកស្រង់ពីរបាយការណ៍របស់អាណត្តិនៅអំឡុងឆ្នាំ 1986-2011 ដែលកំណត់តាមប្រធានបទ[25]។

**គំនិតផ្តួចផ្តើមប្រឆាំងការធ្វើទារុណកម្ម**

នៅឆ្នាំ 2013 អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម បានបើក**វេទិកាតាមបណ្តាញអ៊ីនធើរណែត**ដែលមានព័ត៌មានស្តីពីសកម្មភាពតាមដានបន្ត ដោយរួមបញ្ចូលរបាយការណ៍ការសង្កេតរបាយការណ៍តាមផ្នែក និងរបាយការណ៍តាមប្រទេសទាំងអស់ បូករួមនឹងសេចក្តីប្រកាសព័ត៌មាន បទសម្ភាសន៍ សន្និសីទ សវនាការ អត្ថបទវិចារណកថា និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត

[25] www.ohchr.org/EN/Issues/FreedomReligion/Pages/Standards.aspx

ដែលពាក់ព័ន្ធនឹងការតាមដានបន្តលើការចុះពិនិត្យតាមប្រទេស និងរបាយការណ៍តាមផ្នែក[26]។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

- រៀបចំ[27] ឬចូលរួមក្នុងព្រឹត្តិការណ៍បន្ថែមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្តីពីប្រធានបទនៃរបាយការណ៍តាមផ្នែក
- សំអាងលើលទ្ធផលរកឃើញ និងអនុសាសន៍នៃរបាយការណ៍តាមផ្នែកដើម្បីពង្រឹងសកម្មភាពរបស់តួអង្គសង្គមស៊ីវិល (ឧ. ការតស៊ូមតិ ការកសាងសមត្ថភាព ការបង្កើនការយល់ដឹង ការពិនិត្យតាមដាន)។

**5.4 ការពិនិត្យឡើងវិញតាមដំណាក់កាលជារួម**

វដ្តទី 1 នៃការពិនិត្យឡើងវិញតាមដំណាក់កាលជារួមបានបញ្ចប់នៅខែ តុលា ឆ្នាំ 2011 នៅពេលដែលរដ្ឋសមាជិកទាំងអស់របស់សហប្រជាជាតិបានធ្វើការពិនិត្យឡើងវិញ។ ក្នុងអំឡុងវដ្តពិនិត្យឡើងវិញទី 2 និងជាបន្តបន្ទាប់ រដ្ឋភាគីត្រូវផ្តល់ព័ត៌មាននៃការចាត់វិធានការក្នុងការអនុវត្តអនុសាសន៍ពីការពិនិត្យឡើងវិញលើកទី 1 និងវឌ្ឍនភាពផ្សេងទៀត។ ក្រៅពីនេះ អាចមានការធ្វើបច្ចុប្បន្នភាពជាប្រចាំក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្រោមចំណុចទី 6 នៃរបៀបវារៈស្តីពី UPR។ រដ្ឋ និងអង្គការ NGO សុទ្ធអាចផ្តល់ព័ត៌មានបច្ចុប្បន្នភាពតាមរយៈរបាយការណ៍បណ្តោះអាសន្ន សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់។

[26] http://antitorture.org

[27] ការរៀបចំព្រឹត្តិការណ៍បន្ថែមគឺសម្រាប់តែអង្គការ NGO ដែលមានតួនាទីពិគ្រោះយោបល់ ECOSOC ប៉ុណ្ណោះ។

**ការរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សស្តីពីការអនុវត្ត UPR ក្នុងប្រទេសកូឡុំប៊ី**

គណៈកម្មការអ្នកច្បាប់របស់កូឡុំប៊ី តែងផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងអំឡុងការជជែកដេញដោលទូទៅក្រោមចំណុចទី 6 ដែលផ្តោតលើ UPR។ តាមរយៈព័ត៌មានបច្ចុប្បន្នភាពទាំងនេះ គណៈកម្មការកូឡុំប៊ីបានផ្តល់ព័ត៌មានស្តីពីវឌ្ឍនភាពរបស់រដ្ឋាភិបាលកូឡុំប៊ីក្នុងការអនុវត្តអនុសាសន៍ UPR។

**តើសង្គមស៊ីវិលអាចចូលរួមបានដោយរបៀបណា?**

- នៅពេលបញ្ជូនព័ត៌មាន ដែលត្រូវបញ្ចូលក្នុងខ្លឹមសារសង្ខេបនៃរបាយការណ៍របស់ភាគីពាក់ព័ន្ធ ត្រូវរួមបញ្ចូលការវិភាគពីរបៀបដែលរដ្ឋបាន ឬមិនបានអនុវត្តអនុសាសន៍នៃវដ្តទី 1។
- តួអង្គសង្គមស៊ីវិលអាចផ្តលព័ត៌មានពីការពិនិត្យឡើងវិញលើរដ្ឋ ជាពិសេសរដ្ឋដែលបង្កើតអនុសាសន៍ក្នុងការពិនិត្យឡើងវិញលើកទី 1 ស្តីពីការវិភាគរបស់ខ្លួនលើវឌ្ឍនភាពនៃការអនុវត្តរបស់រដ្ឋ។
- អង្គការ NGO ដែលមានតួនាទីពិគ្រោះយោបល់ ECOSOC អាចធ្វើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ទៅកាន់ក្រុមប្រឹក្សាសិទ្ធមនុស្សក្រោមចំណុចទី 6 ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តអនុសាសន៍ UPR របស់រដ្ឋ។

សម្រាប់ការណែនាំស្តីពីការចូលរួមរបស់សង្គមស៊ីវិលក្នុងស្ថាប័នទាំងនេះ សូមអានសៀវភៅណែនាំរបស់ OHCHR សម្រាប់សង្គមស៊ីវិល ៖ *ការធ្វើការជាមួយកម្មវិធីសិទ្ធិមនុស្សរបស់សហប្រជាជាតិ* និងការណែនាំអនុវត្តស្តីពីការពិនិត្យឡើងវិញតាមដំណាក់កាលជារួម[28]។

[28] www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx

## ឧបករណ៍តាមដានបន្តស្តីពី UPR

UPR-Info របស់អង្គការ NGO បានបង្កើតឧបករណ៍ដើម្បីសម្របសម្រួល លើកកម្ពស់ និងពិនិត្យតាមដានការអនុវត្តអនុសាសន៍ UPR ជាពិសេស ៖

- កម្មវិធីតាមដានបន្តដែលពិនិត្យឡើងវិញលើការអនុវត្តអនុសាសន៍រយៈពេល 2 ឆ្នាំបន្ទាប់ពីវដ្តទី 1 (ការវាយតម្លៃការអនុវត្តពាក់កណ្តាលអាណត្តិ) និងប្រៀបធៀបអនុសាសន៍ និងការប្តេជ្ញាចិត្តក្នុងវដ្តទី 1 ជាមួយនឹងព័ត៌មានរបស់រដ្ឋស្តីពីការអនុវត្តដែលមានបញ្ជាក់ក្នុងរបាយការណ៍ថ្នាក់ជាតិរបស់ខ្លួនសម្រាប់វដ្តទី 2 នៃ UPR។
- ការសិក្សាពី ***ការឆ្ពោះទៅរកការអនុវត្ត*** ដែលវិភាគព័ត៌មាន និងទិន្នន័យចងក្រងក្នុងកម្មវិធីតាមដានបន្តដែលពិនិត្យឡើងវិញលើការអនុវត្តអនុសាសន៍ 3,294 ក្នុងចំណោមអនុសាសន៍ 6,542 ដែលលើកឡើងសម្រាប់ 66 ប្រទេស។
- **កម្រងឯកសារតាមដានបន្តសម្រាប់សង្គមស៊ីវិល** ដែលគ្រោងពីសកម្មភាពជាអនុសាសន៍ចំនួន 5 ៖ 1) ការផ្សព្វផ្សាយអនុសាសន៍ UPR និងការប្តេជ្ញាចិត្តជាសាធារណៈ 2) ការរៀបចំផែនការ និងការអនុវត្ត 3) ការចូលរួមក្នុងកិច្ចសន្ទនាជាមួយរដ្ឋដែលត្រូវបានពិនិត្យឡើងវិញដើម្បីចូលរួមក្នុងការអនុវត្ត 4) ការពិនិត្យតាមដានការអនុវត្ត និង 5) ការរាយការណ៍ពីការអនុវត្ត[29]។

Organisation Internationale de la Francophonie បានបោះពុម្ព**សៀវភៅណែនាំអនុវត្ត**ស្តីពីការអនុវត្តអនុសាសន៍ UPR និងការប្តេជ្ញាចិត្ត។ ដោយផ្តោតសំខាន់លើរដ្ឋនានា សៀវភៅណែនាំនេះក៏ពាក់ព័ន្ធនឹងភាគីពាក់ព័ន្ធផ្សេងៗ ដូចជា តួអង្គសង្គមស៊ីវិលផងដែរ ពោលគឺសមត្ថភាពរបស់សង្គមស៊ីវិលក្នុងនាមជារដ្ឋដៃគូក្នុងការតាមដានបន្ត និងការអនុវត្ត។ សៀវភៅណែនាំនេះស្នើឲ្យមានការបន្តអនុវត្តតាមរយៈផែនការអនុវត្តដែលមាន 10 ជំហាន៖

1. ប្រមូលព័ត៌មានពាក់ព័ន្ធ
2. ចងក្រងតាមផ្នែក

[29] www.upr-info.org/followup/

3. កំណត់សកម្មភាពរំពឹងទុក និងលទ្ធផលដែលកើតចេញពីអនុសាសន៍

4. កំណត់វិធានការអនុវត្ត

5. អនុម័តវិធីសាស្ត្រចម្រុះសម្រាប់វិស័យនីមួយៗ

6. កំណត់ការទទួលខុសត្រូវសម្រាប់ការអនុវត្តនៅកម្រិតរដ្ឋ

7. កំណត់ដៃគូអនុវត្តនៅថ្នាក់ជាតិ

8. កំណត់រយៈពេលកំណត់សម្រាប់ការអនុវត្ត

9. កំណត់ការកសាងសមត្ថភាព និងតម្រូវការជំនួយបច្ចេកទេស និងដៃគូអនុវត្តនៅថ្នាក់អន្តរជាតិ

10. បង្កើតយុទ្ធសាស្ត្រតាមដានបន្ត និងការវាយតម្លៃសម្រាប់ការអនុវត្ត[30]។

**5.5 វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ**

ក្នុងផ្នែកនេះ នីតិវិធីតាមដានបន្ត និងការអនុវត្តដែលបង្កើតឡើងដោយយន្តការផ្សេងៗត្រូវបានបង្ហាញដាច់ដោយឡែកពីគ្នា ដោយសារតែ ទោះបីជាមានលក្ខណៈស្រដៀងគ្នាក្តី ក៏វាបង្កើតជាលក្ខណៈដោយឡែកៗសម្រាប់យន្តការនីមួយៗ។ យ៉ាងនេះក្តី ត្រូវរំលឹកឡើងវិញបន្ថែមទៀតថា ការតាមដានបន្តកាន់តែមានប្រសិទ្ធភាព ប្រសិនបើធ្វើឡើងបានគ្រប់ជ្រុងជ្រោយ ចំណែកអនុសាសន៍របស់យន្តការសិទ្ធិមនុស្សផ្សេងៗពង្រឹងឲ្យគ្នាទៅវិញទៅមក និងបង្កើនសក្តានុពលរបស់ខ្លួនឆ្ពោះទៅរកការអនុវត្ត។ សូមមើលផ្នែកទី 3 នៃសៀវភៅណែនាំនេះ។

**5.6 ការសងសឹក**

ការសងសឹងលើបុគ្គល និងក្រុមដែលព្យាយាមសហការ ឬបានសហការជាមួយអង្គការសហប្រជាជាតិ តំណាងរបស់សហប្រជាជាតិ និងយន្តការក្នុងផ្នែកសិទ្ធិមនុស្សរបស់ខ្លួន គឺជាការរំលោភសិទ្ធិមនុស្ស។ ក្រៅពីនេះ ការសងសឹងអាចកើតមានឡើង នៅពេលដែលសង្គមស៊ីវិលព្យាយាមសហការជាមួយយន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិ ក្នុងក្របខ័ណ្ឌសកម្មភាពតាមដានបន្តរបស់ខ្លួន។

[30] www.francophonie.org

សេចក្តីសម្រេចលេខ 12/1 របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានកំណត់ឲ្យអគ្គលេខាធិការដាក់របាយការណ៍មួយរាល់ឆ្នាំទៅក្រុមប្រឹក្សា ដែលមានការចងក្រង និងការវិភាគការចោទប្រកាន់ពីករណីសងសឹកលើបុគ្គលដែលសហការជាមួយយន្តការសិទ្ធិមនុស្សរបស់សហប្រជាជាតិ និងអនុសាសន៍ស្តីពីរបៀបដោះស្រាយការគំរាមកំហែង និងការសងសឹក[31]។

ក្រៅពីករណីនៃការសងសឹកដែលពាក់ព័ន្ធនឹងកិច្ចសហការជាមួយក្រុមប្រឹក្សា នីតិវិធីពិសេស និងសន្និសញ្ញា ដូចជា នីតិវិធីតាមដានបន្ត និងការអនុវត្ត របាយការណ៍នេះអាចរួមបញ្ចូលការសងសឹកដែលពាក់ព័ន្ធនឹងកិច្ចសហការជាមួយ OHCHR ការងារតាមមូលដ្ឋានរបស់ OHCHR និងទីប្រឹក្សាសិទ្ធិមនុស្ស ក្រុមប្រចាំប្រទេសរបស់សហប្រជាជាតិ សមាសធាតុសិទ្ធិមនុស្សនៃបេសកកម្មរក្សាសន្តិភាព។ល។ ព័ត៌មានតាមដានបន្តស្តីពីករណីទាំងនេះដែលរួមបញ្ចូលក្នុងរបាយការណ៍ពីមុនក៏ពាក់ព័ន្ធ និងគួរលើកមកបង្ហាញផងដែរ។

ការសងសឹកអាចកើតឡើងលើបុគ្គលដែល ៖

- ព្យាយាមសហការ ឬបានសហការជាមួយអង្គការសហប្រជាជាតិ តំណាងរបស់ខ្លួន និងយន្តការក្នុងផ្នែកសិទ្ធិមនុស្ស ឬដែលបានផ្តល់សក្ខីកម្ម ឬព័ត៌មានដល់ពួកគេ
- ប្រើប្រាស់ ឬបានប្រើប្រាស់នីតិវិធីដែលបង្កើតឡើងក្រោមអំណាចរបស់សហប្រជាជាតិសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និង/ឬបានផ្តល់ជំនួយផ្នែកច្បាប់ ឬជំនួយផ្សេងទៀតដល់ពួកគេសម្រាប់គោលបំណងនេះ
- បញ្ជូន ឬបានបញ្ជូនទំនាក់ទំនងក្រោមនីតិវិធីដែលបង្កើតឡើងដោយលិខិតុបករណ៍សិទ្ធិមនុស្ស និង/ឬ បានផ្តល់ជំនួយផ្នែកច្បាប់ ឬជំនួយផ្សេងទៀតដល់ពួកគេសម្រាប់គោលបំណងនេះ
- ជាសាច់ញាតិរបស់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស ឬសាច់ញាតិរបស់អ្នកដែលបានផ្តល់ជំនួយផ្នែកច្បាប់ ឬជំនួយផ្សេងទៀតដល់ជនរងគ្រោះ។

[31] សម្រាប់របាយការណ៍ឆ្នាំ 2012 និង 2011 សូមមើល A/HRC/21/18 និង A/HRC/18/19។

ការផ្សព្វផ្សាយករណីសងសឹកតាមរយៈរបាយការណ៍របស់អគ្គលេខាធិការ អាចផ្តល់ការការពារល្អប្រសើរ ប៉ុន្តែហានិភ័យនៃការបង្ហាញជាសាធារណៈក៏ត្រូវមានការវាយតម្លៃដោយប្រុងប្រយ័ត្នផងដែរ។ សម្រាប់មូលហេតុនេះ របាយការណ៍រួមបញ្ចូលតែករណីដែលបុគ្គលពាក់ព័ន្ធបានផ្តល់ការយល់ព្រមត្រឹមត្រូវឲ្យមានការបោះពុម្ពផ្សាយករណីរបស់ខ្លួនប៉ុណ្ណោះ។

ដើម្បីដាក់បញ្ជូនព័ត៌មានស្តីពីការសងសឹក សូមទាក់ទង ៖ reprisal@ohchr.org។

6. ការស្វែងយល់បន្ថែម

- គេហទំព័ររបស់ OHCHR ៖ www.ohchr.org
- ឧបករណ៍របស់ OHCHR សម្រាប់សង្គមស៊ីវិលមានក្នុង ៖ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx ដែលសរសេរជាភាសាផ្លូវការទាំង 6 របស់សហប្រជាជាតិ។
- សន្ទស្សន៍សិទ្ធិមនុស្សជាសកល ៖ http://uhri.ohchr.org/
- សេវាអន្តរជាតិសម្រាប់សិទ្ធិមនុស្ស និងមជ្ឈមណ្ឌលច្បាប់ស្តីពីសិទ្ធិមនុស្ស ៖ **ការអនុវត្តក្នុងប្រទេសនូវអនុសាសន៍សិទ្ធិមនុស្សរបស់សហប្រជាជាតិ ៖ សៀវភៅណែនាំសម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអ្នកតស៊ូមតិ** ៖ www.ishr.ch
- La Francophonie សៀវភៅណែនាំអនុវត្តស្តីពីការពិនិត្យឡើងវិញតាមដំណាក់កាលជារួម ឆ្នាំ 2013 ៖ www.francophonie.org
- **ចាប់ពីសាលក្រមរហូតដល់យុត្តិធម៌ ៖ ការអនុវត្តសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្សថ្នាក់តំបន់និងអន្តរជាតិ ឆ្នាំ 2010 និងចាប់ពីសិទ្ធិរហូតដល់ការផ្តល់សំណង ៖ រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រសម្រាប់ការអនុវត្តសេចក្តីសម្រេចស្តីពីសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ 2013** ៖ www.opensocietyfoundation.org។
- ការផ្សព្វផ្សាយតាមបណ្តាញអ៊ីនធើណែត
  - **Web TV របស់សហប្រជាជាតិ** ៖ http://webtv.un.org
  - កិច្ចប្រជុំរបស់សន្ធិសញ្ញា ៖ www.treatybodywebcast.org
- សៀវភៅណែនាំសម្រាប់អ្នកអនុវត្តស្តីពីសិទ្ធិមនុស្សក្នុងការថែទាំអ្នកជំងឺ ៖ http://health-rights.org/
- ករណីសិក្សាស្តីពីសកម្មភាពតាមដានបន្តលើការសង្កេតរួមរបស់ CRC ៖ www.childrightsnet.org/NGOGroup/CRC/FollowUp/
- មូលដ្ឋានទិន្នន័យរបស់ក្រុមការងារទទួលបន្ទុកការឃុំឃាំងតាមទំនើងចិត្ត ៖ www.unwgaddatabase.org/un/
- **អត្ថបទដកស្រង់ស្តីពីសេរីភាពសាសនា ឬជំនឿ** ៖

www.ohchr.org/EN/Issues/FreedomReligion/Pages/Standards.aspx

អង្គការ NGO មួយចំនួនមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយយន្តការសិទ្ធិមនុស្សជាក់លាក់។ ពួកគេសម្របសម្រួល និងគាំទ្រការចូលរួមរបស់តួអង្គសង្គមស៊ីវិលជាមួយយន្តការទាំងនោះ និងអាចផ្តល់ការណែនាំ និងការគាំទ្រ។ អង្គការ NGO ទាំងនោះរួមមាន ៖

- មជ្ឈមណ្ឌលសិទ្ធពលរដ្ឋ និងសិទ្ធនយោបាយ (មជ្ឈមណ្ឌល CCPR) សម្រាប់ ICCPR
- បណ្តាញសិទ្ធិកុមារ សម្រាប់ CRC
- សម្ព័ន្ធជនពិការអន្តរជាតិ (IDA) សម្រាប់ CRPD
- ចលនាអន្តរជាតិប្រឆាំងគ្រប់ទម្រង់នៃការរើសអើង និងការប្រកាន់ពូជសាសន៍ (IMADR) សម្រាប់ CERD
- វេទិកាអន្តរជាតិ ៖ អនុសញ្ញាស្តីពីពលករទេសន្តរប្រវេសន៍ (IPMWC) សម្រាប់ CMW
- ក្រុមប្រឹក្សាស្តារនីតិសម្បទាអន្តរជាតិសម្រាប់ជនរងគ្រោះនៃការធ្វើទារុណកម្ម (IRCT) សម្រាប់ CAT
- អង្គការឃ្លាំមើលសិទ្ធិស្ត្រីអន្តរជាតិ (IWRAW) ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិចសម្រាប់ CEDAW
- UPR-Info សម្រាប់ UPR។

7. ព័ត៌មានទំនាក់ទំនង

ផ្នែកសង្គមស៊ីវិលរបស់ OHCHR អាចទាក់ទងតាមព័ត៌មានដូចខាងក្រោម ៖

civilsociety@ohchr.org

ទូរស័ព្ទ ៖ +41 (0) 22 917 9656

សៀវភៅណែនាំស្តីពីសិទ្ធិមនុស្សរបស់ OHCHR និងសៀវភៅណែនាំអនុវត្តសម្រាប់សង្គមស៊ីវិល មានតាមបណ្តាញអ៊ីនធើរណែតជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញក្នុងគេហទំព័រ ៖ www.ohchr.org/EN/AboutUs/Pages/CivilSociety.aspx។

ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីម៉ែលរបស់សង្គមស៊ីវិល ផ្តល់ព័ត៌មានបច្ចុប្បន្នភាព និងការណែនាំស្តីពីអាណត្តិ និងយន្តការសិទ្ធិមនុស្សទាំងអស់ ព្រមទាំងព័ត៌មាន និងកាលបរិច្ឆេទកំណត់សម្រាប់ការស្នើសុំមូលនិធិ លុយជំនួយ និងសម្ព័ន្ធភាព។ ដើម្បីចូលរួម សូមចូលទៅកាន់គេហទំព័ររបស់សង្គមស៊ីវិល ឬ http://goo.gl/08snt

ដើម្បីអបអរខួបទី 20 ឆ្នាំនៃការបើកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ៖

*"សង្គមស៊ីវិលបានវិវឌ្ឍ និងពង្រីកខ្លួន ដោយមានអង្គការសិទ្ធិមនុស្សជាតិដ៏សកម្ម និងអ្នកការពារសិទ្ធិមនុស្សកាន់តែច្រើននៅពេលបច្ចុប្បន្ននេះជាងកាលពី 20 ឆ្នាំមុន។ អង្គការ និងបុគ្គលទាំងនេះបានលះបង់អាយុជីវិតដើម្បីបុព្វហេតុសិទ្ធិមនុស្ស ៖ ពួកគេជាអ្នកជំរុញឲ្យមានការផ្លាស់ប្តូរ ជាអ្នកដាស់តឿន ឬផ្តល់ព័ត៌មានស្តីពីការរំលោភបំពាន កង្វះការអនុវត្តច្បាប់/បទប្បញ្ញត្តិ និងអំណាចនិយម។ សៀវភៅណែនាំអនុវត្តនេះគឺដើម្បីអបអរខួបគម្រប់ 20 ឆ្នាំរបស់ OHCHR និងឧទ្ទិសដល់តួអង្គសង្គមស៊ីវិលដែលធ្វើការលើផ្នែកសិទ្ធិមនុស្សនៅទូទាំងពិភពលោក"។*

Navi Pillay

ឧត្តមស្នងការអង្គការសហប្រជាជាតិ

ទទួលបន្ទុកសិទ្ធិមនុស្ស

ខែ តុលា ឆ្នាំ 2013

សៀវភៅណែនាំអនុវត្តសម្រាប់សង្គមស៊ីវិល

របៀបតាមដានបន្តលើអនុសាសន៍ស្តីពីសិទ្ធិមនុស្សរបស់សហប្រជាជាតិ

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)


Palais des Nations

CH 1211 ទីក្រុងហ្សឺណែវ 10 ប្រទេសស្វីស

ទូរស័ព្ទ ៖ +41 (0) 22 917 90 00

ទូរសារ ៖ +41 (0) 22 917 90 08

www.ohchr.org